# ព្រះរាជក្រម

នស/រកម/១២០៧/០៣៤

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

លេខ ...
ថ្ងៃខែឆ្នាំ ... ម៉ោង ...
បញ្ជូនទៅ ...

លេខ ៥៣១
ថ្ងៃទី ...
បញ្ជូនទៅ ...

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងក្របខ័ណ្ឌ សម្រាប់តំបន់ពាណិជ្ជកម្មសេរី អាស៊ាន-កូរ៉េ ដែលរដ្ឋសភា បានអនុម័តកាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាពុំអាចមានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យ និងឱ្យយោបល់តាមលក្ខខណ្ឌកំណត់ក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញបានឡើយ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់

# ស្តីពី

# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង
# ក្របខ័ណ្ឌសម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងក្របខ័ណ្ឌ សម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ ដែលធ្វើនៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី នាថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៥ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ ។

រាជធានីភ្នំពេញថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ ២០០៧
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

នស/រកម.០៧១២.០២៦

**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
**ហត្ថលេខា**
**គាត ឈន់**

លេខ: [illegible] ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ [illegible] ឆ្នាំ២០០៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# កិច្ចព្រមព្រៀងក្របខណ្ឌ
# ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋាភិបាលនៃប្រទេសសមាជិក
# នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង សាធារណរដ្ឋកូរ៉េ

រដ្ឋាភិបាលនៃប្រ៊ុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និង សាធារណរដ្ឋសង្គមនិយមវៀតណាម ប្រទេសសមាជិកនៃប្រជាជាតិអាស៊ីអគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ

**ដោយរំលឹកឡើងវិញ** នូវសេចក្តីសំរេចដែលបានធ្វើនៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន-កូរ៉េ នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ នៅទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ដោយការប្រកាសរួមស្តីពីភាពជាដៃគូសហប្រតិបត្តិការទូលំទូលាយរវាងអាស៊ាន និងកូរ៉េ ដើម្បីបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ នៅតំណាក់កាលតំបូងបំផុតជាមួយនឹងការផ្តល់នូវប្រព្រឹត្តកម្មពិសេស និងដោយខ្សែកនិងការផ្តល់ភាពទន់ភ្លន់បន្ថែមចំពោះប្រទេសសមាជិកអាស៊ានថ្មីដែលមាន ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ សភាពមីយ៉ាន់ម៉ា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

**ដោយប្រាថ្នា** អនុម័តនូវកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងអាស៊ាន និងកូរ៉េ ដើម្បីបន្តជំរុញការរីកលូតលាស់ និងការអភិវឌ្ឍន៍ លើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន និងនាំមកនូវផលប្រយោជន៍យ៉ាងផុសផុលក្នុងតំបន់ក្នុងរយៈពេលវែងទៅមុខ

**ដោយជឿជាក់ថា** ការបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ គឺជាការពង្រឹកដោយឯកឯងនូវទំនាក់ទំនងដែលមានស្រាប់ ក៏ដូចជាជំហានឆ្ពោះទៅរកការលើកកំពស់ទំនាក់ទំនងឱ្យកាន់តែទូលំទូលាយថែមទៀត

**ដោយអះអាងជាថ្មី** នូវការជឿជាក់រួមថាការសំរុះសំរួលដើម្បីបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ គួរលើគោលការណ៍ទូលំទូលាយដែលបានឯកភាពគ្នាក្នុងរបៀបធ្វើសេរីកម្មដុំកំភួន និងប្រកបដោយអត្ថន័យ ៧

ការធ្វើឱ្យប្រសើរផលប្រយោជន៍ទៅវិញទៅមក និងគោរពតាមតាមវិន័យ និងវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO)

**ដោយកសាង** ផ្អែកលើសិទ្ធិ និងកាតព្វកិច្ចរៀងៗខ្លួនក្រោមកិច្ចព្រមព្រៀងម៉ារ៉ាកេសស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក និងកិច្ចព្រមព្រៀងទាំងឡាយផ្សេងទៀតដែលបានចរចាក្រោមកិច្ចព្រមព្រៀងនេះ និងឧបករណ៍សហប្រតិបត្តិការពហុភាគី និងទ្វេភាគី ដែលបណ្តាភាគីបានចូលរួម

**ដោយទទួលស្គាល់ថា** ការលុបចោលឧបសគ្គពាណិជ្ជកម្មតាមរយៈការបង្កើត តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ និងរួមចំណែកដល់ការអភិវឌ្ឍន៍សុខដុម និងការពង្រីកពាណិជ្ជកម្មពិភពលោក ព្រមទាំងផ្តល់កាតាលីករដល់សហប្រតិបត្តការអន្តរជាតិទូលំទូលាយជាង ជាពិសេសនៅក្នុងអាស៊ីខាងកើត

**ដោយទទួលស្គាល់** សារៈសំខាន់នៃការកសាងសមត្ថភាពតាមរយៈការអភិវឌ្ឍន៍ធនធានមនុស្សដើម្បីប្រឈមទៅនឹងសកលភាវូបនីយកម្ម និង

**ដោយទទួលស្គាល់** គំរិតគតខុសគ្នានៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ក្នុងចំណោមប្រទេសសមាជិកអាស៊ាន និងតម្រូវការនៃភាពបត់បែនដែលត្រូវផ្តល់ទៅឱ្យប្រទេសសមាជិកអាស៊ានថ្មី ជាពិសេសសេចក្តីត្រូវការក្នុងការសំរួលការចូលរួមកាន់តែច្រើន ឡើងថែមទៀតក្នុងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនៃបណ្តាភាគី និងការពង្រីកការនាំចេញរាប់បញ្ចូលទាំងតាមរយៈការពង្រឹងសមត្ថភាព ប្រសិទ្ធភាព និងភាពមានប្រៀបក្នុងស្រុក

បានព្រមព្រៀងដូចតទៅនេះ ៖

## ជំពូក ១

## បទបញ្ញត្តិទូទៅ

### មាត្រា ១,១

### គោលដៅ

គោលដៅនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះគឺ :

ក- ពង្រឹង និងធ្វើឱ្យប្រសើរសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគក្នុងចំណោមបណ្តាភាគី

ខ- ធ្វើសេរីកម្មជាបណ្តើរៗ និងជំរុញពាណិជ្ជកម្មទំនិញ និងសេវា ព្រមទាំងការបង្កើតរបបវិនិយោគដែលមានតម្លាភាព សេរី និងងាយស្រួល

គ- រុករកវិស័យថ្មីៗដទៃទៀត និងបង្កើតវិធានការសមស្របសំរាប់សមាហរណកម្ម និងសហប្រតិបត្តិការស្អិតរមួត

ឃ- សំរួលសមាហរណកម្មសេដ្ឋកិច្ចឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀតនៃប្រទេសសមាជិកអាស៊ានថ្មី និងលុបបំបាត់គំលាតអភិវឌ្ឍន៍ក្នុងចំណោមបណ្តាភាគី

ង- បង្កើតក្របខ័ណ្ឌសហប្រតិបត្តិការសំរាប់ការពង្រឹងថែមទៀតទំនាក់ទំនងសេដ្ឋកិច្ចក្នុងចំណោមបណ្តាភាគី

### មាត្រា ១,២

### និយមន័យ

សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ លើកលែងតែបរិបទតម្រូវផ្សេងពីនេះ ÷

**អេអ៊ីអឹម + កូរ៉េ** មានន័យថា រដ្ឋមន្ត្រីសេដ្ឋកិច្ចនៃប្រទេសសមាជិកអាស៊ាន និងរដ្ឋមន្ត្រីពាណិជ្ជកម្មកូរ៉េ

**អាស៊ាន** មានន័យថា សមាគមប្រជាជាតិអាស៊ីអគ្នេយ៍ដែលមាន ប្រ៊ុយណេដារ៉ូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ។

**តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ** មានន័យថា តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េដែលបង្កើតឡើងដោយកិច្ចព្រមព្រៀងក្របខ័ណ្ឌ និងកិច្ចព្រមព្រៀងពាក់ព័ន្ធទាំងឡាយដូចមានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រាទី ១.៤

**បណ្តាប្រទេសសមាជិកអាស៊ាន** មានន័យថា ប្រ៊ុយណេដារ៉ូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាមរួមគ្នា

**ប្រទេសសមាជិកអាស៊ាន** មានន័យថា ប្រ៊ុយណេដារ៉ូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាមនីមួយៗ

**កិច្ចព្រមព្រៀងក្របខ័ណ្ឌ** មានន័យថា កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយក្នុងចំណោមរដ្ឋាភិបាលនៃប្រទេសសមាជិកអាស៊ាន និងសាធារណរដ្ឋកូរ៉េ

GATS មានន័យថា កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវា ដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក

**GATT ១៩៩៤** មានន័យថា កិច្ចព្រមព្រៀងទូទៅស្តីពីអត្រាពន្ធនាំចូល និងពាណិជ្ជកម្មឆ្នាំ ១៩៩៤ រាប់បញ្ចូលទាំងអត្ថបទ និងបទប្បញ្ញត្តិបន្ថែម ដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក

**គណៈកម្មការអនុវត្ត** មានន័យថា គណៈកម្មការអនុវត្តបង្កើតឡើងក្រោមមាត្រា ៥.៣ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ[៧]

**កូរ៉េ** មានន័យថា សាធារណរដ្ឋកូរ៉េ

**ប្រទេសសមាជិកអាស៊ានថ្មី** មានន័យថា ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ សហភាពមីយ៉ាន់ម៉ា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

**ប្រភេទធម្មតា** មានន័យថា បញ្ជីបន្ទាត់ពន្ធពន្ធដែលអត្រាពន្ធអនុវត្តប្រជាជាតិអនុគ្រោះបំផុតនឹងត្រូវបន្ថយបន្តបន្ទាប់ និងឈានទៅលុបបំបាត់ស្របតាមរបៀបដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធ ១ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ

**បណ្តាភាគី** មានន័យថា បណ្តាប្រទេសអាស៊ាន និងកូរ៉េរួមគ្នា

**ភាគី** មានន័យថា ប្រទេសសមាជិកអាស៊ាន និងកូរ៉េ

WTO មានន័យថា អង្គការពាណិជ្ជកម្មពិភពលោក

**កិច្ចព្រមព្រៀងរបស់ WTO** មានន័យថា កិច្ចព្រមព្រៀងម៉ារ៉ាកេសដែលបង្កើតអង្គការពាណិជ្ជកម្មពិភពលោក នៅថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៩៤ និងបណ្តាកិច្ចព្រមព្រៀងផ្សេងទៀតដែលបានចរចាក្រោមកិច្ចព្រមព្រៀងនេះ

**មាត្រា ១.៣**

**វិធានការសំរាប់ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយ**

បណ្តាភាគីនឹងបង្កើតស្របតាមមាត្រា ២៤ នៃ GATT ឆ្នាំ ១៩៩៤ និងមាត្រា ៥ នៃ GATS តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ និងពង្រឹង និងធ្វើឱ្យប្រសើរសហប្រតិបត្តិការសេដ្ឋកិច្ចតាមរយៈវិធានការដូចតទៅនេះ :

ក- បំបាត់ជាបណ្តើរនូវពន្ធនាំចូល របាំងមិនមែនពន្ធនាំចូល លើពាណិជ្ជកម្មទំនិញស្ទើរតែទាំងអស់

ខ- ធ្វើសេរីកម្មជាបណ្តើរនូវពាណិជ្ជកម្មសេវាស្ទើរតែគ្រប់ផ្នែក

គ- បង្កើតរបបវិនិយោគបើកចំហ និងប្រកួតប្រជែងដែលសំរួល និងជំរុញវិនិយោគក្នុងចំណោមបណ្តាភាគី។

ឃ- ផ្តល់ប្រព្រឹត្តិកម្មពិសេស និងដោយឡែកទៅឱ្យប្រទេសសមាជិកអាស៊ាន និងភាពទន់ភ្លន់ថែមទៀតទៅឱ្យប្រទេសសមាជិកអាស៊ានថ្មី ដូចបានឯកភាពនៅក្នុងសេចក្តីថ្លែងការណ៍រួមស្តីពីភាពជាដៃគូសហប្រតិបត្តិការទូលំទូលាយរវាងអាស៊ាន និងកូរ៉េ ព្រមទាំងសមាសធាតុគន្លឹះភ្ជាប់មកជាមួយនេះ

ង- ផ្តល់ភាពទន់ភ្លន់ទៅឱ្យបណ្តាភាគីនៅក្នុងការចរចាតំបន់ពាណិជ្ជកម្មសេរីអាស៊ាន - កូរ៉េ ដើម្បីដោះស្រាយវិស័យវេទយិតក្នុងផ្នែកទំនិញសេវា និងវិនិយោគ។ ភាពទន់ភ្លន់នេះត្រូវចរចា និងឯកភាពគ្នាផ្អែកលើគោលការណ៍ បដិការ និងផលប្រយោជន៍ទៅវិញទៅមក

ច- រុករកផ្លូវ និងមធ្យោបាយដើម្បីពង្រីកភាពជាដៃគូសេដ្ឋកិច្ចលើវិស័យថ្មី១ និងពង្រីកសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងវិស័យដែលអាចឯកភាពគ្នាក្នុងចំណោមបណ្តាភាគី ដែលនឹងបំពេញឱ្យការពង្រឹងទំនាក់ទំនងពាណិជ្ជកម្មវិនិយោគក្នុងចំណោមបណ្តាភាគី

ឆ- បង្កើតនីតិវិធី និងយន្តការសមស្របដើម្បីការអនុវត្តន៍ដោយប្រសិទ្ធិភាពនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ

## មាត្រា ១.៤
## ទំហំសាលភាពច្បាប់ និង ទំនាក់ទំនងទៅកិច្ចព្រមព្រៀងផ្សេងទៀត

១ - កិច្ចព្រមព្រៀងដូចខាងក្រោមនេះ គឺជាផ្នែកមួយនៃឧបករណ៍ច្បាប់ដែលបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន - កូរ៉េ នៅពេលចូលជាធរមានរៀង១ខ្លួន :

ក- កិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ ( រាប់បញ្ចូលទាំងឧបសម្ព័ន្ធស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ច)

ខ- កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះដូចមានចែងនៅក្នុង

គ- កិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាដែលត្រូវចុះហត្ថលេខាស្របតាមមាត្រា ២.២

ឃ- កិច្ចព្រមព្រៀងវិនិយោគ ដែលត្រូវចុះហត្ថលេខាស្របតាមមាត្រា ២.៣

ង- កិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយវិវាទនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌដូចមានចែងក្នុងមាត្រា ៥.១

ច-កិច្ចព្រមព្រៀងណាផ្សេងទៀតដែលអាចឯកភាពគ្នាទៅវិញទៅមកដោយឯកច្ឆ័ន្ទ និងចុះហត្ថលេខាដោយបណ្តាភាគីក្នុងបរិបទនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន - កូរ៉េ

២- កិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ ឬសកម្មភាពណាមួយដែលធ្វើក្រោមកិច្ចព្រមព្រៀងនេះ លើកលែងតែមានចែងផ្សេងពីនៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌ មិនត្រូវប៉ះពាល់ ឬមោឃៈសិទ្ធិ និងកាតព្វកិច្ចនៃភាគីក្រោមកិច្ច ~

ព្រមព្រៀងដែលមានស្រាប់ ដែលភាគីបានចុះហត្ថលេខា ។

៣- គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះរារាំងប្រទេសសមាជិកអាស៊ាននីមួយៗចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគីជាមួយបណ្តាប្រទេសសមាជិកអាស៊ានផ្សេងទៀត និង ឬក្នុងការពាក់ព័ន្ធដល់ពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវា វិនិយោគ និង ឬវិស័យសហប្រតិបត្តិការសេដ្ឋកិច្ចផ្សេងទៀត ។ បទបញ្ញត្តិនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះនឹងមិនអនុវត្តទៅលើកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគីណាមួយឡើយ ។

## ជំពូក ២

## សេរីកម្ម

### មាត្រា ២.១

### ពាណិជ្ជកម្មទំនិញ

១- បណ្តាភាគីត្រូវបន្ថយជាបន្តិចម្តងៗ និងឈានទៅបំបាត់ពន្ធនាំចូល និងបទបញ្ជារឹតត្បិតពាណិជ្ជកម្មផ្សេងទៀត (លើកលែងតែបទបញ្ជាទាំងឡាយណា នៅពេលចាំបាច់អនុញ្ញាតក្រោមមាត្រា ២៤.៨ បេ និង GATT ១៩៩៤) លើពាណិជ្ជកម្មទំនិញស្ទើរតែទាំងអស់ក្នុងចំណោមបណ្តាភាគី ស្របតាមបទបញ្ញត្តិនៃកម្មវិធីសំរាប់ប្រភេទធម្មតាក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ ។

២- កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌត្រូវរាប់បញ្ចូលទាំងអស់ តែក៏មិនកំណត់ត្រឹម :

ក- វិធានលំអិតណែនាំការបន្ថយពន្ធនាំចូលបន្តិចម្តងៗ និង ឬកម្មវិធីលុបចោលពន្ធនាំចូល

ខ- វិធានដើមកំណើតទំនិញ

គ- ការកែប្រែការសន្យា

ឃ- វិធានការមិនមែនពន្ធ វិធានការអនាម័យ និងភូតគាមអនាម័យ និងរបាំងបច្ចេកទេសពាណិជ្ជកម្ម

ង- វិធានការការពារ និង

ច- វិន័យ WTO និងការបន្ថយ និងការលុបរបាំងមិនមែនពន្ធនាំចូល

## មាត្រា ២.២

## ពាណិជ្ជកម្មសេវា

១- បណ្តាភាគីត្រូវធ្វើសេរីកម្មជាបណ្តើរៗ ពាណិជ្ជកម្មសេវាក្នុងចំណោមបណ្តាភាគីស្របតាមមាត្រា៥ នៃ GATS លើវិសាលភាពវិស័យជាច្រើន ។

២- សំរាប់គោលបំណងនេះ បណ្តាភាគីត្រូវចាប់ផ្តើមចរចាអំពីសេរីកម្មជាបណ្តើរៗ នៃពាណិជ្ជកម្មសេវា ។ សេរីកម្មបែបនេះត្រូវឈានទៅរក :

ក- បទបញ្ញត្តិសំរាប់អវត្តមាន ឬការលុបការរើសអើងស្ទើរតែទាំងស្រុងក្នុងចំណោមបណ្តាភាគីសំរាប់តែវិស័យដែលស្ថិតក្រោមកថាខ័ណ្ឌ ១ តាមរយៈ

- ការលុបវិធានការរើសអើងដែលមាន និង ឬ

- ការហាមឃាត់វិធានការរើសអើងថ្មី ឬបន្ថែមអំពីពាណិជ្ជកម្មសេវាក្នុងចំណោមភាគី ទោះជានៅពេលចូលជាធរមាននៃកិច្ចព្រមព្រៀងដូចចែងក្នុងកថាខ័ណ្ឌ ៣ ឬលើមូលដ្ឋាននៃក្របខ័ណ្ឌពេលវេលាឯកភាពគ្នា លើកលែងតែវិធានការអនុញ្ញាតឱ្យក្រោមមាត្រា ១១ ១២ ១៤ស្ទួន នៃ GATS

ខ-ការពង្រីកឱ្យបានជ្រៅ និងការពង្រីកវិសាលភាពនៃសេរីកម្មពាណិជ្ជកម្មសេវា លើសពីអ្វីដែលបានធ្វើដោយបណ្តាភាគីក្រោម GATS និង

គ-សហប្រតិបត្តិការបន្ថែមទៀតនៃសេវាក្នុងចំណោមបណ្តាភាគីដើម្បីធ្វើឱ្យប្រសើរប្រសិទ្ធិភាព និងភាពប្រជែងព្រមទាំងពង្រីកការផ្តល់ និងការបែងចែកសេវានៃអ្នកផ្តល់សេវារៀងៗខ្លួននៃបណ្តាភាគី ។

៣- បណ្តាភាគីត្រូវចាប់ផ្តើមចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវានៅដើមឆ្នាំ ២០០៦ ក្នុងទិសដៅបញ្ចប់មិនឱ្យយឺតជាងថ្ងៃ ៣១ ខែ ធ្នូ ឆ្នាំ ២០០៦ ។

## មាត្រា ២.៣

## វិនិយោគ

១- បណ្តាភាគីត្រូវបង្កើតរបបវិនិយោគសេរី ងាយស្រួល មានតម្លាភាព និងមានភាពប្រជែងប្រកបដោយបរិដ្ឋានធុរកិច្ចស្និទ្ធស្នាល ។

២- សំរាប់បំណងនេះ បណ្តាភាគីត្រូវចាប់ផ្តើមចរចាអំពីសេរីកម្មរបបវិនិយោគ ។ ការចរចានេះត្រូវឈានទៅរក :

ក-សេរីកម្មជាបណ្តើរៗនៃរបបវិនិយោគ

ខ-ការពង្រឹងសហប្រតិបត្តិការវិនិយោគ ការសំរួលវិនិយោគ និងការធ្វើឱ្យប្រសើរតម្លាភាពនៃបទបញ្ជា និង វិធានវិនិយោគ

គ-ការផ្តល់ការការពារក្រោមរបបវិនិយោគ

៣- បណ្តាភាគីត្រូវចាប់ផ្តើមការចរចាកិច្ចព្រមព្រៀងវិនិយោគនៅដើមឆ្នាំ ២០០៦ ដើម្បីបញ្ចប់ការចរចាមិនយឺតជាងថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៦ ។

## មាត្រា ២.៤
## ប្រព្រឹត្តកម្មប្រជាជាតិអនុគ្រោះបំផុត

កូរ៉េត្រូវផ្តល់ទៅឱ្យប្រទេសសមាជិកអាស៊ានទាំងអស់ដែលពុំមែនជាសមាជិក WTO នូវប្រព្រឹត្តិកម្មប្រជាជាតិអនុគ្រោះបំផុតស្របតាមវិធាន និងវិន័យ WTO នៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន ។

## ជំពូក ៣
## សហប្រតិបត្តិការសេដ្ឋកិច្ច

## មាត្រា ៣.១
## ទំសាលភាព និង ការអនុវត្តន៍សហប្រតិបត្តិការ

១- បណ្តាភាគី ឈរលើមូលដ្ឋានផលប្រយោជន៍ទៅវិញទៅមកត្រូវវិវរក និងអនុវត្តគំរោងសហប្រតិបត្តិការវិស័យដូចខាងក្រោមនេះ :

ក- និតិវិធីគយ

ខ- ការជំរុញពាណិជ្ជកម្ម និងវិនិយោគ

គ- សហគ្រាសធុនតូច និងមធ្យម

ឃ- ការគ្រប់គ្រងធនធានមនុស្ស និងការអភិវឌ្ឍន៍

ង- ទេសចរណ៍

ច- វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

ឆ- សេវាហិរញ្ញវត្ថុ

ជ- ពត៌មាន និងបច្ចេកវិទ្យាគមនាគមន៍

ឈ- កសិកម្ម នេសាទ ការចិញ្ចឹមសត្វ ផលិតផលពីការដាំដុះ និងព្រៃឈើ

ញ- កម្មសិទ្ធិបញ្ញា

ដ- ឧស្សាហកម្មបរិដ្ឋាន

ឋ- ការផ្សព្វផ្សាយ

ឌ- បច្ចេកវិទ្យា និងការសាងសង់

ឍ- ស្តង់ដារ ការវាយតម្លៃនៃភាពស្របតាម និងវិធានការអនាម័យ និងភូតគាមអនាម័យ

ណ- ការយកវ៉ែ

ត- ថាមពល

ថ- ធនធានធម្មជាតិ

ទ- ការស្ថាបនានាវា និងការដឹកជញ្ជូនតាមសមុទ្រ និង

ធ- ភាពយន្ត

២- បណ្តាភាគីត្រូវអនុវត្តគំរោងសហប្រតិបត្តិការសេដ្ឋកិច្ច តាមរយៈពេលដែលបានឯកភាពគ្នា និងកាលណាអាចធ្វើទៅបាន។

គំរោងទាំងនោះត្រូវតាមដានដោយគណៈកម្មការអនុវត្តដើម្បីប្រសិទ្ធិភាពនៃការអនុវត្តន៍ ។

៣- សេចក្តីលំអិតនៃសហប្រតិបត្តិការនេះ មានចែងនៅក្នុងឧបសម្ព័ន្ធស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ច ។

## មាត្រា ៣.២

## កម្មវិធីនៃការកសាងសមត្ថភាព និងជំនួយបច្ចេកទេស

១- ដោយទទួលស្គាល់ថាកម្មវិធីនៃការកសាងសមត្ថភាព និងជំនួយបច្ចេកទេសមានសារៈសំខាន់ ជាពិសេសសំរាប់ប្រទេសសមាជិកអាស៊ានថ្មី និងដើម្បីពង្រីកពាណិជ្ជកម្ម និងវិនិយោគរបស់ខ្លួនជាមួយកូរ៉េ បណ្តាភាគីត្រូវអនុវត្តកម្មវិធីនេះលើមូលដ្ឋានឯកភាពទៅវិញទៅមក ។

២- បណ្តាភាគីត្រូវពង្រឹងសហប្រតិបត្តិការ និងការគាំទ្រដល់ការធ្វើឱ្យសំរេចទិសដៅសមាហរ័ណកម្មអាស៊ានដោយការអនុវត្តន៍គំរោងដែលជំរុញកិច្ចព្រមព្រៀងបាលីទី ២ គំនិតផ្តួចផ្តើមសំរាប់សមាហរ័ណកម្មអាស៊ាន ព្រមទាំងកម្មវិធីសកម្មភាពវៀងច័ន្ទ រាប់បញ្ចូលទាំងការផ្តល់ជំនួយបច្ចេកទេស និងការកសាងសមត្ថភាពដល់ប្រទេសសមាជិកអាស៊ានថ្មីផ្អែកលើបទពិសោធន៍ និងជំនាញរបស់កូរ៉េក្នុងការអភិវឌ្ឍន៍ ។

៣- បណ្តាភាគីត្រូវពង្រឹងការខំប្រឹងប្រែងសមាហរ័ណកម្មអាស៊ាន ដោយបន្ថយគំលាតអភិវឌ្ឍន៍ក្នុងចំណោមប្រទេសសមាជិកអាស៊ាន និងរវាងបណ្តាប្រទេសសមាជិកអាស៊ាន និងកូរ៉េដោយញ៉ាំងឱ្យប្រសើរនូវការអភិវឌ្ឍន៍តំបន់ និងអនុតំបន់ ។

៤- ដោយទទួលស្គាល់គំលាតអភិវឌ្ឍន៍ក្នុងចំណោមប្រទេសសមាជិកអាស៊ាន និងរវាងប្រទេសសមាជិកអាស៊ាន និងកូរ៉េ បណ្តាភាគីត្រូវធ្វើឱ្យប្រសើរការអភិវឌ្ឍន៍តំបន់ និងអនុតំបន់តាមរយៈគំនិតផ្តួចផ្តើមសហប្រតិបត្តិការរាប់បញ្ចូលទាំង :

ក- អនុតំបន់មេគង្គ

ខ- យុទ្ធសាស្ត្រសហប្រតិបត្តិការ អាយ៉ាវ៉ាឌីចៅប្រាយ៉ាមេគង្គ

គ- តំបន់អភិវឌ្ឍន៍អាស៊ានប្រ៊ុយណេដារូសាឡឹម ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន

ឃ- ត្រីកោណអភិវឌ្ឍន៍ដូចជា ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ថៃឡង់ដ៍ និង ឥណ្ឌូណេស៊ី ម៉ាឡេស៊ី សឹង្ហបូរី ។

ង- កម្មវិធីនៃមហាអនុតំបន់មេគង្គ

ច- របៀងសេដ្ឋកិច្ចបូព៌ា - បស្ចឹមទី២

ឆ- សហប្រតិបត្តិការអភិវឌ្ឍន៍អាងមេគង្គអាស៊ាន

ជ- គំរោងផ្លូវដែក សឹង្ហបុរី គុណមិញ

ឈ- ការបែងចែកបទពិសោធន៍ជាមួយគណៈកម្មការទន្លេមេគង្គក្នុងការរៀបចំ និងអនុវត្តកម្មវិធីអាទិភាពក្នុងអាងទន្លេមេគង្គ ។

## ជំពូក ៤
## វិស័យផ្សេងទៀត

### មាត្រា ៤.១
### ការពង្រីកភាពជាដៃគូសេដ្ឋកិច្ចទៅលើវិស័យថ្មី

ក្នុងទិសដៅសំរេចតំបន់ពាណិជ្ជកម្មសេរីទូលំទូលាយអាស៊ាន-កូរ៉េ បណ្តាភាគីត្រូវរិះរកផ្លូវ និងមធ្យោបាយពង្រីកភាពជាដៃគូសេដ្ឋកិច្ចទៅក្នុងវិស័យថ្មី ជាពិសេសសំដែលមានផលប្រយោជន៍ទៅវិញទៅមក និងដោយការឯកភាពនៃបណ្តាភាគី ។

## ជំពូក ៥
## អវសានបញ្ញត្តិ

### មាត្រា ៥.១
### ការដោះស្រាយវិវាទ

១- វិវាទណាមួយអំពីការបកស្រាយការអនុវត្តន៍កិច្ចព្រមព្រៀងក្របខ័ណ្ឌនេះត្រូវដោះស្រាយតាមនីតិវិធី និងយន្តការដូចមានចែងក្នុងកិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយវិវាទក្រោមកិច្ចព្រមព្រៀងនេះ ។

២- ទោះបីជាមានកថាខ័ណ្ឌ ១ វិវាទណាក៏ដោយកើតពីកថាខ័ណ្ឌ ៣ នៃមាត្រា ២.២ ( ពាណិជ្ជកម្មសេវា ) កថាខ័ណ្ឌ ៣ នៃមាត្រា ២.៣ ( វិនិយោគ ) ជំពូក៣ ( សហប្រតិបត្តិការសេដ្ឋកិច្ច ) និង ជំពូក៤ ( វិស័យផ្សេងៗទៀត ) និង ឧបសម្ព័ន្ធស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ច ត្រូវតែស្ថិតនៅក្រោមកិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយវិវាទក្រោមកិច្ចព្រមព្រៀងនេះ ។/

## មាត្រា ៥.២
## កិច្ចសម្របសម្រួលស្ថាប័នសំរាប់ការចរចា

១- គណៈកម្មការចរចាពាណិជ្ជកម្មអាស៊ាន-កូរ៉េត្រូវបង្កើតឡើងដើម្បីធ្វើការចរចាដូចមានចែងក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ ។

២- គណៈកម្មការចរចាពាណិជ្ជកម្មអាស៊ាន-កូរ៉េ អាចបង្កើតក្រុមការងារបើចាំបាច់ ដើម្បីជួយគណៈកម្មការនេះក្នុងការធ្វើការចរចាវិស័យពិសេសដោយឡែកនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ ។

៣- បណ្តាភាគីត្រូវខិតខំរាំងខ្ទប់ការចាត់វិធានការរឹតត្បិតពាណិជ្ជកម្មណាមួយដែលអាចនាំឱ្យប៉ះពាល់ជាអវិជ្ជមានដល់ជំហរចរចានៃភាគីផ្សេងណាមួយ នៅពេលចាប់ផ្តើមការចរចាភ្លាម ដូចដែលបានគ្រោងទុកក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌ និងបន្តរហូតដល់ការបញ្ចប់ជាផ្លូវការនៃការចរចានេះនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៦។

## មាត្រា ៥.៣
## ការអនុវត្តន៍កិច្ចព្រមព្រៀងក្របខ័ណ្ឌ

១- រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងកូរ៉េត្រូវមានអំណាចចុងក្រោយអំពីបញ្ហាទាំងឡាយពាក់ព័ន្ធដល់ការអនុវត្តន៍កិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ និងកិច្ចព្រមព្រៀងផ្សេងទៀតដែលបានចុះហត្ថលេខា ឬនឹងត្រូវចុះ ហត្ថលេខាស្របតាម កិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ ។ គណៈកម្មការអនុវត្តដែលនឹងបង្កើតឡើងនិងដែល មានសមាសភាពជាមន្ត្រីសេដ្ឋកិច្ចជាន់ខ្ពស់ នៃនៃបណ្តាភាគី ឬមន្ត្រីដែលបានចាត់ត្រូវប្រជុំគ្នានៅពេលសមស្រប ដើម្បីទទួលមុខងារបែបនេះដូចមានចែងក្នុងកថាខ័ណ្ឌ ២ ក្រោមការត្រួតពិនិត្យ និងការណែនាំរបស់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងកូរ៉េ ។

២- តាមរយៈគណៈកម្មការអនុវត្ត បណ្តាភាគីត្រូវ :

ក-សម្របសម្រួល ត្រួតពិនិត្យការអនុវត្តន៍បទបញ្ញត្តិនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ និងកិច្ចព្រមព្រៀងផ្សេងទៀតដែលបានចុះហត្ថលេខា ឬនឹងត្រូវចុះហត្ថលេខាស្របតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ៖

ខ-ពិនិត្យឡើងវិញការអនុវត្តន៍កិច្ចព្រមព្រៀងក្របខ័ណ្ឌ និងកិច្ចព្រមព្រៀងផ្សេងទៀតដែលបានចុះហត្ថលេខា ឬនឹងត្រូវចុះហត្ថលេខាស្របតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ

គ-ត្រួតពិនិត្យការងាររបស់គណៈកម្មការ និងក្រុមការងារដែលបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ និង កិច្ចព្រមព្រៀងផ្សេងទៀតដែលបានចុះហត្ថលេខា ឬនឹងត្រូវចុះហត្ថលេខាស្របតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ

ឃ-ពិចារណាបញ្ហាផ្សេងណាមួយដែលអាចប៉ះពាល់ដល់ប្រតិបត្តិការនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ និងកិច្ចព្រមព្រៀងផ្សេងទៀតដែលបានចុះហត្ថលេខា ឬនឹងត្រូវចុះហត្ថលេខាស្របតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ឬដែលប្រគល់ឱ្យទៅគណៈកម្មការអនុវត្តដោយបណ្ដាភាគី

៣- ក្នុងការបំពេញមុខងារ គណៈកម្មការអនុវត្តអាច :

ក-បង្កើត ផ្ទេរការទទួលខុសត្រូវ និង បគល់កិច្ចការពិសេសទៅឱ្យគណៈកម្មការអចិន្ត្រៃយ៍ ក្រុមការងារ ឬក្រុមជំនាញបណ្ដោះអាសន្ន

ខ- បើបណ្ដាភាគីឯកភាព ធ្វើសកម្មភាពផ្សេងទៀតក្នុងការបំពេញភារកិច្ចរបស់ខ្លួន

៤- គណៈកម្មការអនុវត្តត្រូវរាយការណ៍ទៅរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងកូរ៉េពីសកម្មភាពរបស់ខ្លួនជាទៀងទាត់ ។

៥- គណៈកម្មការអនុវត្តអាចបង្កើតវិធាន និងនីតិវិធីដែលត្រូវយល់ព្រមដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងកូរ៉េ ។

៦- គណៈកម្មការអនុវត្តត្រូវប្រជុំនៅក្នុងឆ្នាំ ក្រោយការចូលជាធរមាននៃកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ បន្ទាប់មកទៀត ១ ឆ្នាំម្ដង ឬផ្សេងពីនេះតាមការសមស្រប ។

## មាត្រា ៥.៤
## លេខាធិការដ្ឋាន និងចំណុចទំនាក់ទំនង

១- លេខាធិការដ្ឋានអាស៊ានសំរាប់ប្រទេសសមាជិកអាស៊ាន និងក្រសួងការបរទេស និងពាណិជ្ជកម្មនៃកូរ៉េសំរាប់ប្រទេសកូរ៉េត្រូវផ្ដល់ការគាំទ្រចាំបាច់ដល់លេខាធិការដ្ឋាន ដើម្បីគោលបំណងនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ និងកិច្ចព្រមព្រៀងទាំងឡាយផ្សេងៗទៀតដែលបានចុះហត្ថលេខា ឬនឹងត្រូវចុះហត្ថលេខាពេលខាងមុខស្របតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌ,

នេះ។ លេខាធិការដ្ឋានអាស៊ាន និងក្រសួងការបរទេស និងពាណិជ្ជកម្មកូរ៉េត្រូវតាមដាន និងរាយការណ៍ទៅគណៈកម្មការអនុវត្តពីការអនុវត្តន៍កិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ និងកិច្ចព្រមព្រៀងផ្សេងទៀតដែលបានចុះហត្ថលេខារួចហើយ ឬដែលនឹងត្រូវចុះហត្ថលេខាស្របតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ ។

២- ទំនាក់ទំនង ឬការជូនពត៌មានផ្លូវការក្នុងចំណោមបណ្តាភាគីដើម្បីគោលបំណងនៃការអនុវត្តន៍កិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ និងកិច្ចព្រមព្រៀងផ្សេងទៀតដែលបានចុះហត្ថលេខារួចហើយ ឬដែលនឹងត្រូវចុះហត្ថលេខាស្របតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ ត្រូវធ្វើឡើង តាមការសមស្របជាភាសាអង់គ្លេសតាមរយៈលេខាធិការដ្ឋានអាស៊ាន និងក្រសួងការបរទេស និងពាណិជ្ជកម្មកូរ៉េ។

៣- បណ្តាភាគីត្រូវចាត់ចំណុចទំនាក់ទំនងរៀង១ខ្លួន ដើម្បីសំរួលដល់ទំនាក់ទំនងផ្សេងទៀតទៅវិញទៅមកលើបញ្ហាណាមួយនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ និងកិច្ចព្រមព្រៀងផ្សេងទៀតដែលបានចុះហត្ថលេខារួចហើយ ឬនឹងត្រូវចុះហត្ថ - លេខាស្របតាមកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ។ តាមសំណូមពររបស់ភាគី ចំណុចទំនាក់ទំនងនៃភាគី ធ្វើសំណូមពរត្រូវស្វែងរកការិយាល័យនៃមន្ត្រីទទួលបន្ទុកបញ្ហាខាងលើហើយ និងជួយក្នុងការសំរួលទំនាក់ទំនងជាមួយភាគីធ្វើសំណូមពរ។

## មាត្រា ៥.៥
## ឧបសម្ព័ន្ធ និង លិខិតតូបករណ៍ពេលអនាគត

១- ឧបសម្ព័ន្ធស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ច គឺផ្នែកមួយនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ។
២- បណ្តាភាគីអាចអនុម័តលិខិតតូបករណ៍ពេលអនាគត អនុលោមតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ។ នៅពេលចូលជាធរមានលិខិតតូបករណ៍ទាំងនេះ គឺជាផ្នែកមួយនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ។

## មាត្រា ៥.៦
## វិសោធនកម្ម

បទបញ្ញត្តិ និងកិច្ចព្រមព្រៀងនេះអាចត្រូវកែប្រែតាមរយៈវិសោធនកម្មដោយការឯកភាពទៅវិញទៅមកជាលាយ...

ល័ក្ខអក្សរដោយបណ្ដាភាគី ។

## មាត្រា ៥.៧
## កន្លែងតម្កល់ទុកឯកសារ

សំរាប់ប្រទេសសមាជិកអាស៊ាន កិច្ចព្រមព្រៀងនេះត្រូវរក្សាទុកដោយអគ្គលេខាធិការអាស៊ាន ដែលត្រូវផ្ដល់ច្បាប់បញ្ជាក់ទៅគ្រប់ប្រទេសសមាជិកអាស៊ាន ។

## មាត្រា ៥.៨
## ការចូលជាធរមាន

១- កិច្ចព្រមព្រៀងក្របខ័ណ្ឌនេះត្រូវចូលជាធរមាននៅថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០៦ ដរាបណាយ៉ាងហោចណាស់ប្រទេសសមាជិកអាស៊ានមួយ និងកូរ៉េដែលនៅក្នុងចំណោមប្រទេសហត្ថលេខីបានជូនពត៌មានជាលាយល័ក្ខអក្សរ ទៅបណ្ដាភាគី ផ្សេងទៀតអំពីការបញ្ចប់នីតិវិធីក្នុងស្រុករបស់ខ្លួន។ ក្នុងករណីដែលកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះមិនបានចូលជាធរមាននៅថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០៦ កិច្ចព្រមព្រៀងនេះនឹងចូលជាធរមាននៅថ្ងៃទី ១ នៃខែទី ២ បន្ទាប់ពីការបរិច្ឆេទចុងក្រោយនេះ ដែលយ៉ាងហោចណាស់ប្រទេសសមាជិកអាស៊ាន១ និងកូរ៉េបានជូនពត៌មានទៅគ្រប់ភាគីជាលាយល័ក្ខអក្សរទៅបណ្ដាភាគីផ្សេងទៀតអំពីការបញ្ចប់នីតិវិធីក្នុងស្រុករបស់ខ្លួន។

២- នៅពេលបញ្ចប់នីតិវិធីក្នុងស្រុកសំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ ភាគីត្រូវជូនពត៌មានជាលាយល័ក្ខអក្សរទៅគ្រប់ភាគីទាំងអស់។

៣-ក្នុងករណីដែលភាគីណាមួយមិនអាចបញ្ចប់នីតិវិធីក្នុងស្រុកសំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ នៅកាលបរិច្ឆេទកំណត់នៅក្នុងកថាខ័ណ្ឌទី ១ កិច្ចព្រមព្រៀងក្របខ័ណ្ឌនេះត្រូវចូលជាធរមានសំរាប់ភាគីនោះនៅកាលបរិច្ឆេទនៃការជូនពត៌មានពីការបញ្ចប់នីតិវិធីក្នុងស្រុក ។

**ជាសក្ខីភាព** អ្នកចុះហត្ថលេខាខាងក្រោមនេះ បានចុះហត្ថលេខាដោយមានការអនុញ្ញាតិស្របច្បាប់ កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយក្នុងចំណោមរដ្ឋាភិបាលនៃប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ ។

**ធ្វើនៅ** កូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី នៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៥ ជាពីរច្បាប់ជាភាសាអង់គ្លេស ។

សំរាប់រដ្ឋាភិបាលប្រ៊ូណេដារ៉ូសាឡឹម

ហាជិ ហាសាណាល់ ប៊ូលគិ

ស្តេចស៊ុលតង់ ប្រ៊ូណេដារូសាឡាំ

សំរាប់ព្រះរាជាណាចក្រកម្ពុជា

សម្តេច ហ៊ុន សែន

នាយករដ្ឋមន្ត្រី

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូណេស៊ី

ស៊ូស៊ីឡូ បាមបាំង យូហ្វូយូណូ

ប្រធានាធិបតី

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

ប៊ុនញ៉ាង វ៉ូរ៉ាឈិត

នាយករដ្ឋមន្ត្រី៧

សំរាប់រដ្ឋាភិបាលម៉ាឡេស៊ី

អាប់ប៊ូលឡា អាម៉េត បាដាវី
នាយករដ្ឋមន្ត្រី

សំរាប់រដ្ឋាភិបាលសហភាពមីយ៉ាន់ម៉ា

ស៊ូ វីន
នាយករដ្ឋមន្ត្រី

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន

ក្លូរៀ ម៉ាកាប៉ាហ្គាល់ អារ៉ូយ៉ូ
ប្រធានាធិបតី

សំរាប់សាធារណរដ្ឋសឹង្ហបុរី

លី សៀន ឡុង
នាយករដ្ឋមន្ត្រី ៧

សំរាប់រដ្ឋាភិបាលថៃឡង់ដ៍

ថាក់ស៊ីន ស៊ីណាវ៉ាត្រា

នាយករដ្ឋមន្ត្រី

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម

ផាំ វ៉ាន់ខាយ

នាយករដ្ឋមន្ត្រី

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ

រ៉ូ មូ - យ៉ុន

ប្រធានាធិបតី

...ដ្ឋាន សេវា និងបច្ចេកទេស
...កដ្ឋាន...
លេខ ...៥៨៤...
ថ្ងៃទី ២២.០៧.០៨ ម៉ោង .........
...ញ្ញូនទៅ .........

# កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ

## នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋាភិបាល ប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ និង សាធារណរដ្ឋកូរ៉េ

រដ្ឋាភិបាលនៃប្រ៊ុយណេដារ៉ូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ និង សាធារណរដ្ឋកូរ៉េ

**ដោយរំលឹក** ដល់កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋាភិបាលប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ និងសាធារណរដ្ឋកូរ៉េដែលបានចុះហត្ថលេខានៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៥ នៅកូឡាឡាំពួ ម៉ាឡេស៊ី

**ដោយរំលឹកថែមទៀត** ដល់មាត្រា ១.៣ និង ២.១ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌដែលឆ្លុះបញ្ចាំងការសន្យារបស់ខ្លួនក្នុងការបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន - កូរ៉េ ដែលគ្របដណ្តប់ពាណិជ្ជកម្មទំនិញ

**ដោយបញ្ជាក់ឡើងវិញ** ការសន្យាលុបចោលពន្ធនាំចូល និងបទបញ្ញត្តិរឹតត្បិតពាណិជ្ជកម្មលើពាណិជ្ជកម្មទំនិញស្ទើរតែទាំងអស់រវាងប្រទេសសមាជិកអាស៊ាន និងសាធារណរដ្ឋកូរ៉េនៅក្នុងរយៈពេលបានកំណត់ ទោះជាមានការផ្តល់ភាពទន់ភ្លន់ដល់ភាគីដើម្បីដោះស្រាយវិស័យរសើប ដូចមានចែងក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌ និង

**ដោយទទួលស្គាល់** កំរិតខុសគ្នានៃការអភិវឌ្ឍន៍សេដ្ឋកិច្ចរវាងប្រទេសសមាជិកអាស៊ាន និងសេចក្តីត្រូវការភាពទន់ភ្លន់ដែលត្រូវផ្តល់ឱ្យប្រទេសសមាជិកអាស៊ានថ្មី ជាពិសេសសេចក្តីត្រូវការដើម្បីសំរួលការចូលរួមច្រើនឡើងក្នុងសហប្រតិបត្តិការសេដ្ឋកិច្ចនៃបណ្តាភាគី និងការពង្រីកការនាំចេញរាប់បញ្ចូលទាំងការពង្រឹងភាពអាចប្រជែងបាន ប្រសិទ្ធិភាព និងសមត្ថភាពក្នុងស្រុក

បានព្រមព្រៀងគ្នាដូចខាងក្រោមនេះ ÷

## មាត្រា ១

## និយមន័យ

ដើម្បីគោលបំណងនៃកិច្ចព្រមព្រៀងនេះ លើកលែងតែបរិបទតម្រូវផ្សេងពីនេះ ÷

**អេអ៊ីអឹម+ កូរ៉េ** មានន័យថា រដ្ឋមន្ត្រីសេដ្ឋកិច្ចនៃប្រទេសសមាជិកអាស៊ាន និងរដ្ឋមន្ត្រីពាណិជ្ជកម្មកូរ៉េ

**អត្រាពន្ធអនុវត្តប្រជាជាតិអនុគ្រោះបំផុត** (MFN) :

ក- សំរាប់ប្រទេសសមាជិកអាស៊ានដែលជាសមាជិក WTO រហូតដល់ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥ និងកូរ៉េ មានន័យថា អត្រាពន្ធអនុវត្តរៀងៗខ្លួនរហូតដល់ ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥ និង

ខ- សំរាប់ប្រទេសសមាជិកអាស៊ានដែលមិនមែនជាសមាជិក WTO រហូតដល់ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥ គឺអត្រាពន្ធដែលអនុវត្តចំពោះកូរ៉េរហូតដល់ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥

**អាស៊ាន** មានន័យថា សមាគមប្រជាជាតិអាស៊ីអគ្នេយ៍ដែលមាន ប្រ៊ុយណេដារ៉ូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយម វៀតណាម ។

**តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ** មានន័យថា តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េដែលបង្កើតឡើងដោយកិច្ចព្រមព្រៀងក្របខ័ណ្ឌ និងកិច្ចព្រមព្រៀងពាក់ព័ន្ធទាំងឡាយដូចមានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រាទី ១៤ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ។

**បណ្តាប្រទេសសមាជិកអាស៊ាន** មានន័យថា ប្រ៊ុយណេដារ៉ូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិប តេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាមរួមគ្នា ។

**ប្រទេសសមាជិកអាស៊ាន** មានន័យថា ប្រ៊ុយណេដារ៉ូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាមនិមួយៗ ។

**អាស៊ាន ៦** មានន័យថា ប្រ៊ុយណេដារ៉ូសាឡឹម សាធារណរដ្ឋឥណ្ឌូណេស៊ី ម៉ាឡេស៊ី សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី និងព្រះរាជាណាចក្រថៃឡង់ដ៍ ។

**កិច្ចព្រមព្រៀងក្របខ័ណ្ឌ** មានន័យថា កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋាភិបាលនៃប្រទេសសមាជិកអាស៊ាន និងសាធារណរដ្ឋកូរ៉េ ។

**GATT ១៩៩៤** មានន័យថា កិច្ចព្រមព្រៀងទូទៅស្តីពីអត្រាពន្ធ និងពាណិជ្ជកម្មឆ្នាំ ១៩៩៤ រាប់បញ្ចូលទាំងអត្ថបទ និងបទបញ្ញត្តិបន្ថែមដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀង នៃអង្គការពាណិជ្ជកម្មពិភពលោក ។

**គណៈកម្មការអនុវត្តន៍** មានន័យថា គណៈកម្មការអនុវត្តន៍បង្កើតឡើងក្រោមមាត្រា ៥.៣ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ

**កូរ៉េ** មានន័យថា សាធារណរដ្ឋកូរ៉េ

**ប្រទេសសមាជិកអាស៊ានថ្មី** មានន័យថា ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ សហភាពមីយ៉ាន់ម៉ា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ។

**បណ្តាវិធានមិនមែនពន្ធ** រួមមានទាំងរបាំងមិនមែនពន្ធ ។

**បណ្តាភាគី** មានន័យថា បណ្តាប្រទេសអាស៊ាន និងកូរ៉េរួមគ្នា ។

**WTO** មានន័យថា អង្គការពាណិជ្ជកម្មពិភពលោក ។៧

**កិច្ចព្រមព្រៀងរបស់ WTO** មានន័យថា កិច្ចព្រមព្រៀងម៉ារ៉ាកេសដែលបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ធ្វើនៅថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៩៤ និងបណ្ដាកិច្ចព្រមព្រៀងផ្សេងទៀតដែលបានចរចាក្រោមកិច្ច ព្រមព្រៀងនេះ ។

## មាត្រា ២
## ប្រព្រឹត្តិកម្មជាតិនៅលើបទបញ្ញា និងការយកពន្ធក្នុងស្រុក

ភាគីនីមួយៗត្រូវផ្ដល់ប្រព្រឹត្តិកម្មជាតិទៅឱ្យទំនិញនៃបណ្ដាភាគីទាំងអស់ស្របតាមមាត្រា ៣ នៃ GATT 1994។ ដូចនេះបទបញ្ញត្តិនៃមាត្រា III នៃកិច្ចព្រមព្រៀង GATT 1994 និងត្រូវបញ្ចូល និងគឺជាផ្នែកមួយនៃកិច្ចព្រមព្រៀង នេះ ។

## មាត្រា ៣
## ការលុប និងការបន្ថយពន្ធនាំចូល

១ - ការបន្ថយ ឬកម្មវិធីលុបពន្ធនៃបណ្ដាភាគីនឹងតម្រូវឱ្យអត្រាពន្ធអនុវត្តប្រជាជាតិអនុគ្រោះបំផុតលើផលិតផល ដែលមានក្នុងបញ្ជីបន្ថយជាបន្តបន្ទាប់ និងបើអាច លុបចោលស្របតាមមាត្រានេះ ។

២ - បន្ទាត់ពន្ធគយទាំងអស់ត្រូវស្ថិតក្រោមល័ក្ខខ័ណ្ឌនៃកម្មវិធីកាត់បន្ថយ ឬលុបពន្ធក្រោមកិច្ចព្រមព្រៀងនេះនឹងត្រូវ បែងចែកដូចខាងក្រោមនេះ ÷

ក- ប្រភេទធម្មតា : អត្រាពន្ធអនុវត្តប្រជាជាតិអនុគ្រោះបំផុតនៃបន្ទាត់ពន្ធគយដែលភាគីនីមួយៗ បានដាក់ក្នុងប្រភេទធម្មតាដោយខ្លួនឯងត្រូវបន្ថយ និងលុបបំបាត់ស្របតាមរបៀបកំណត់ក្នុងឧបសម្ព័ន្ធ ១ ក្នុងគោលដៅសំរេចឱ្យបាននូវកំរិតទាបបំផុតនៃទិសដៅ។

ខ- ប្រភេទវេទយិត : អត្រាពន្ធអនុវត្តប្រជាជាតិអនុគ្រោះបំផុតដែលភាគីនីមួយៗ បានដាក់បញ្ចូលក្នុងប្រភេទ វេទយិតដោយខ្លួនឯងត្រូវបន្ថយ ឬលុបបំបាត់ទៅតាមរបៀបកំណត់ក្នុងឧបសម្ព័ន្ធទី ២ ។

៣- ស្ថិតនៅក្រោមល័ក្ខខ័ណ្ឌនៃឧបសម្ព័ន្ធ ១ និង ២ រាល់ការសន្យាដែលបានធ្វើដោយភាគីនីមួយៗ ក្រោមមាត្រានេះ ត្រូវអនុវត្តទៅភាគីទាំងឡាយដទៃទៀត ។៧

## មាត្រា ៤
## តម្លៃគយ

មាត្រាទី ១០នៃកិច្ចព្រមព្រៀង GATT ឆ្នាំ1994 និងត្រូវបញ្ចូល និងគឺជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៥
## វិធានដើមកំណើតទំនិញ

វិធានដើមកំណើតទំនិញ និងនីតិវិធីនៃការចេញវិញ្ញាបនប័ត្រដែលអាចអនុវត្តទៅលើទំនិញនៃកិច្ចព្រមព្រៀងនេះមានចែងនៅក្នុងឧបសម្ព័ន្ធ ៣ និងឯកសារភ្ជាប់ជាមួយឧបសម្ព័ន្ធ។

## មាត្រា ៦
## ការកែប្រែសម្បទាន

១- បណ្តាភាគីមិនត្រូវលុបចោល ឬ រាំងសម្បទានណាមួយនៃកិច្ចព្រមព្រៀងនេះ លើកលែងតែករណីដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង។

២ - គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះហាមឃាត់ភាគីណាមួយមិនឱ្យចរចា និងចុះហត្ថលេខាលើកិច្ចសំរុះសំរួលដើម្បីពន្លឿនការអនុវត្តន៍សម្បទានដែលបានធ្វើក្រោមកិច្ចព្រមព្រៀងនេះ ឬបញ្ចូលទំនិញថ្មីទៅក្នុងសម្បទានឱ្យតែកិច្ចសំរុះសំរួលខាងលើនេះត្រូវបានធ្វើឡើងដោយការឯកភាពទៅវិញទៅមក និងត្រូវអនុវត្តទៅលើភាគីទាំងអស់។

៣- ភាគីណាក៏ដោយ តាមរយៈការចរចា និងការព្រមព្រៀងគ្នាជាមួយភាគីណាមួយផ្សេងទៀតដែលត្រូវផ្តល់សម្បទានអាចកែប្រែ ឬដកហូតសម្បទានខាងលើដែលបានធ្វើក្រោមកិច្ចព្រមព្រៀងនេះ។ នៅក្នុងការចរចា និងការព្រមព្រៀងនេះដែលរាប់បញ្ចូលទាំងការផ្តល់ការប៉ះប៉ូវចំពោះទំនិញផ្សេងទៀត បណ្តាភាគីពាក់ពន្ធ័ត្រូវរក្សាកំរិតទូទៅនៃសម្បទានដែលមានផលប្រយោជន៍ទៅវិញទៅមកចំពោះពាណិជ្ជកម្ម មិនទាបជាងសម្បទានដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះមុនការព្រមព្រៀង ។

៤- ការព្រមព្រៀងណាមួយដោយបណ្តាភាគីដើម្បីកែប្រែ ឬដកហូតសម្បទានដែលបានធ្វើតាមកម្មវិធីនៃការលុប ឬបន្ថយពន្ធនាំចូលស្របតាមកថាខ័ណ្ឌ ៣ ឬដើម្បីពន្លឿនការលុបពន្ធនាំចូលនៅក្នុងកម្មវិធីខាងលើ ឬដើម្បីបញ្ចូលទំនិញទៅក្នុងកម្មវិធីខាងលើស្របតាមកថាខ័ណ្ឌ ២ ត្រូវជំនួសអត្រាពន្ធ ឬផ្លូវដែលបានកំណត់អនុលោមតាមកម្មវិធីនៃការលុបសំរាប់ទំនិញនោះ ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធ ១ និង ២ ត្រូវធ្វើដូចវិសោធនកម្មនៃឧបសម្ព័ន្ធពាក់ព័ន្ធ ហើយត្រូវចូលជាធរមានស្របតាមនីតិវិធីនៃមាត្រា ១៧ ។

## មាត្រា ៧
## វិន័យនៃអង្គការពាណិជ្ជកម្មពិភពលោក

ស្ថិតក្រោមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀងនានាដែលអាចឯកភាពអនុលោម ការសើរើនៃកិច្ចព្រមព្រៀងនេះដោយភាគីទាំងឡាយនៃមាត្រា ១៥ ភាគីនានាឯកភាព និងបញ្ជាក់ឡើងវិញតាមរយៈមាត្រានេះ នូវការសន្យាគោរពបទបញ្ញត្តិនៃវិន័យនៃអង្គការពាណិជ្ជកម្មពិភពលោកដូចមានកំណត់ក្នុងឧបសម្ព័ន្ធ I A និង I C នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកដូចមានវាយក្នុងឧបសម្ព័ន្ធ ៤ ដែលរាប់បញ្ចូលក្នុងចំណោមនោះ វិធានការមិនមែនពន្ធរបាំងបច្ចេកទេសពាណិជ្ជកម្ម ខាងក្រោយនេះ (ហៅថា TBT) វិធានការអនាម័យ និងភូតគាមអនាម័យ (ខាងក្រោមនេះហៅថា SPS) វិធានការប៉ះប៉ូវ វិធានប្រឆាំងនឹងការលក់បន្ថោកថ្លៃ និងសិទ្ធិកម្មសិទ្ធិបញ្ញា ។

## មាត្រា ៨
## វិធានការរឹតត្បិតបរិមាណ វិធានការមិនមែនពន្ធ និង វិធានការអនាម័យ និង ភូតគាមអនាម័យ

១- ភាគីនីមួយៗប្តេជ្ញាចិត្តមិនអនុម័ត ឬរក្សាការហាមឃាត់ ឬការរឹតត្បិតបរិមាណណាមួយលើការនាំចូលទំនិញណាមួយរបស់ភាគីនានាផ្សេងទៀត ឬលើការនាំចេញទំនិញណាមួយសំដៅទៅដែនដីនៃភាគីទាំងឡាយផ្សេងទៀត លើកលែងតែស្របតាមសិទ្ធិ និងកាតព្វកិច្ចនៃអង្គការពាណិជ្ជកម្មពិភពលោក ឬបទបញ្ញត្តិទាំងឡាយផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះ ។

២ - ភាគីនីមួយៗ ត្រូវធានាតម្លាភាពនៃវិធានការមិនមែនពន្ធ តែគេមិនបានរៀបចំអនុម័ត ឬអនុវត្តដើម្បីបង្កើតឧបសគ្គមិនចាំបាច់ដល់ពាណិជ្ជកម្មនៃភាគីទាំងឡាយ។ ភាគីនានាត្រូវរកឱ្យឃើញរបាំងមិនមែនពន្ធក្រៅពីការរឹត

ត្បិតបរិមាណដើម្បីបំបាត់យ៉ាងលឿនបំផុតក្រោយការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ រយៈពេលនៃការបំបាត់របាំងមិនមែនពន្ធត្រូវឯកភាពគ្នាទៅវិញទៅមកដោយភាគីទាំងអស់ ។

៣- ភាគីទាំងឡាយទទួលស្គាល់សារៈសំខាន់នៃតម្លាភាពរបស់បទបញ្ញា TBT និង SPS ដូចមានចែងក្នុងកិច្ចព្រមព្រៀងទាំងឡាយ និងអង្គការពាណិជ្ជកម្មពិភពលោកស្តីពី TBT និង SPS រាប់បញ្ចូលទាំងនីតិវិធីនៃការជូនដំណឹងអំពីការរៀបចំបទបញ្ញា និងស្តង់ដាររបស់ TBT និងអំពីការកើតឡើងនៃករណី SPS ដើម្បីបន្ថយឥទ្ធិពលអវិជ្ជមានរបស់វាមកលើពាណិជ្ជកម្ម ព្រមទាំងការការពារជីវិត ឬសុខភាពរបស់មនុស្ស សត្វ និងរុក្ខជាតិ។ ភាគីនីមួយៗត្រូវចាត់តាំងចំណុចទំនាក់ទំនងដើម្បីឆ្លើយតបទៅនឹងសំណួរពាក់ព័ន្ធដល់មាត្រានេះ។

៤- ក្រុមការងារស្តីពី TBT និង SPS (ខាងក្រោយនេះហៅថាក្រុមការងារ TBT និង SPS) នៅក្រោមគណៈកម្មការអនុវត្ត នឹងត្រូវបង្កើតឡើងដើម្បីដោះស្រាយបញ្ហានានាពាក់ព័ន្ធដល់ការអនុវត្តន៍នៃមាត្រានេះ និងសំរួលពាណិជ្ជកម្ម និងការពារជីវិត និងសុខភាព មនុស្ស សត្វ និងរុក្ខជាតិ តាមរយៈសហប្រតិបត្តិការទៅវិញទៅមក និងការពិគ្រោះទ្វេភាគី។ ក្រុមការងារ TBT និង SPS មានសមាសភាពមន្ត្រីរដ្ឋាភិបាល ពីទីភ្នាក់ងារកសិកម្ម នេសាទ ការចិញ្ចឹមសត្វ និងសុខាភិបាល និងទីភ្នាក់ងារពាក់ព័ន្ធទាំងឡាយទៀត។ ក្រុមការងារ TBT និង SPS នេះត្រូវរៀបចំទំហំការងារ និងផែនសកម្មភាពរបស់ខ្លួន និងជួបជុំគ្នាយ៉ាងតិចបំផុតម្តងក្នុងមួយឆ្នាំ តាមការឯកភាពគ្នាទៅវិញទៅមកដោយភាគីនានា។

**មាត្រា ៩**

**វិធានការការពារ**

១- ភាគីនីមួយៗដែលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក រក្សាសិទ្ធិ និងកាតព្វកិច្ចក្រោមមាត្រា ១៩ នៃកិច្ចព្រមព្រៀង GATT ឆ្នាំ ១៩៩៤ និងកិច្ចព្រមព្រៀងនៃអង្គការពាណិជ្ជកម្មពិភពលោកស្តីពីការការពារ។ សកម្មភាពនានាដែលធ្វើស្របតាមមាត្រាទី ១៩ នៃកិច្ចព្រមព្រៀង GATT ឆ្នាំ ១៩៩៤ និងកិច្ចព្រមព្រៀងនៃ អង្គការពាណិជ្ជកម្មពិភពលោកស្តីពីការការពារ ពុំស្ថិតក្រោមល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយវិវាទក្រោម កិច្ចព្រមព្រៀងក្របខ័ណ្ឌ ។[៧]

២- ចំពោះវិធានការការពារនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ ភាគីមានសិទ្ធិផ្តួចផ្តើមវិធានការបែបនេះសំរាប់ទំនិញនៅក្នុងរយៈពេលអន្តរកាលសំរាប់ទំនិញនោះ ។ រយៈពេលអន្តរកាលសំរាប់ទំនិញត្រូវចាប់ផ្តើមពីកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ និងបញ្ចប់ ៧ ឆ្នាំក្រោយពីការបញ្ចប់ការកាត់បន្ថយ ឬការលុបចោលពន្ធនាំចូលសំរាប់ទំនិញនោះ ។

៣- ស្ថិតក្រោមល័ក្ខខ័ណ្ឌនៃកថាខ័ណ្ឌខាងក្រោមនៃមាត្រានេះ ភាគីមានសិទ្ធិចាត់វិធានការការពារនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ បើឥទ្ធិពលនៃការបំពេញកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ រាប់បញ្ចូលទាំងសម្បទានពន្ធនាំចូល ឬបើលទ្ធផលនៃព្រឹត្តិការណ៍ដែលមិនបានគ្រោងទុក និងនៃឥទ្ធិពលរបស់កាតព្វកិច្ចដោយភាគី ទំនិញកំពុងនាំចូលពីភាគីទាំងឡាយផ្សេងទៀត និងដែលបានទទួលសម្បទានពន្ធនាំចូល ក្នុងបរិមាណកើនឡើងបើប្រៀបទៅនឹងផលិតផលក្នុងស្រុក ហើយក្រោមល័ក្ខខ័ណ្ឌដែលបង្ក ឬគំរាមកំហែង និងបង្កយ៉ាងខ្លាំងក្លានូវការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុកនៃប្រទេសនាំចូលដែលផលិតផលិតផលដូចគ្នា ឬផលិតផលប្រកួតប្រជែងនៅក្នុងដែនដីរបស់ខ្លួន ។

៤ - បើវិធានការការពារនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ ត្រូវបានចាត់ ភាគីដែលចាត់វិធានការនេះត្រូវ :

ក- ព្យួរការបន្ថយថែមទៀតនៃពន្ធនាំចូលនៃទំនិញដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ

ខ- បង្កើនពន្ធនាំចូលនៃទំនិញពាក់ព័ន្ធទៅដល់កំរិតដែលមិនលើសពី :

- អត្រាពន្ធអនុវត្ត MFN លើទំនិញជាធរមាននៅពេលដែលសកម្មភាពត្រូវបានចាត់
- អត្រាពន្ធអនុវត្ត MFN លើទំនិញជាធរមាននៅកាលបរិច្ឆេទមុនបន្តិច កាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ

៥ - វិធានការការពារណាមួយនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ អាចរក្សាទុកសំរាប់រយៈពេលបឋម ៣ ឆ្នាំ និងអាចពន្យារសំរាប់រយៈពេលមិនលើស ១ ឆ្នាំ បើវិធានការនោះត្រូវបានកំណត់ស្របតាមនីតិវិធីចែងនៅក្នុងកថាខ័ណ្ឌ ៦ ថា វិធានការនោះនៅតែចាំបាច់សំរាប់បង្ការ និងជួសជុលការខូចខាតធ្ងន់ធ្ងរ និងដើម្បីសំរួលការកែតម្រូវ និងត្រូវមានភ័ស្តុតាងបញ្ជាក់ថាឧស្សាហកម្មក្នុងស្រុកកំពុងធ្វើការកែតម្រូវ ។ ទោះជាមានរយៈកាលនៃវិធានការការពារនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េក៏ដោយ ក៏វិធានការនេះត្រូវបញ្ចប់នៅទីបញ្ចប់នៃរយៈពេលអន្តរកាលសំរាប់ទំនិញនោះ ។

៦ - ក្នុងការអនុវត្តន៍នៃវិធានការការពារនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ បណ្តាភាគីត្រូវអនុម័តវិធានសំរាប់ការអនុវត្តន៍ វិធានការការពារ រាប់បញ្ចូលទាំងវិធានការបណ្តោះអាសន្នដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង WTO ស្តីពីការការពារ លើកលែងតែវិធានការរឹតត្បិតបរិមាណដែលមានចែងនៅក្នុងមាត្រា ៥ និង មាត្រា ៩ ១៣ ១៤ នៃកិច្ចព្រមព្រៀង WTO ស្តីពីការការពារ ។ តាមរបៀបនេះ រាល់បទបញ្ញត្តិផ្សេងទៀតនៃកិច្ចព្រមព្រៀង WTO ស្តីពីការការពារ តាមការជាក់ស្តែង ត្រូវបញ្ចូលទៅជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ ។

៧- វិធានការការពារនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ មិនត្រូវអនុវត្តប្រឆាំងនឹងទំនិញដែលមានដើមកំណើតពីដែនដីនៃភាគី ដរាបណាចំណែកនាំចូលទំនិញនោះនៅក្នុងប្រទេសនាំចូលមិនលើស ៣% នៃការនាំចូលសរុបពីបណ្តាភាគី ។

៨- ក្នុងការស្វែងរកការប៉ះប៉ូវក្រោមមាត្រា ៨ នៃកិច្ចព្រមព្រៀង WTO ស្តីពីការការពារសំរាប់វិធានការការពារនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ បណ្តាភាគីពាក់ព័ន្ធត្រូវស្វែងរកអន្តរាគមន៍សំរុះសំរួលនៃគណៈកម្មការអនុវត្តដើម្បីកំណត់កំរិតសម្បទានសំខាន់ប្រហាក់ប្រហែលទៅនឹងកំរិតដែលមានស្រាប់ក្រោមកិច្ចព្រមព្រៀងនេះ រវាងភាគីដែលចាត់វិធានការការពារ និងភាគីនាំចេញទាំងឡាយដែលរងផលប៉ះពាល់ដោយវិធានការនេះមុនការព្យួរសម្បទានណាមួយដែលប្រហាក់ប្រហែល។ ទម្រង់ការនៃអន្តរាគមន៍សំរុះសំរួលត្រូវបញ្ចប់ក្នុងរយៈពេល ៩០ ថ្ងៃពីកាលបរិច្ឆេទដែលវិធានការការពារនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េត្រូវបានអនុវត្ត ។

៩- ផ្អែកលើការប្តេជ្ញាចិត្តរបស់ភាគីនៃវិធានការការពារលើទំនិញនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ អត្រាពន្ធសំរាប់ទំនិញនោះគឺជាអត្រាពន្ធដែលគួរបានចូលជាធរមាន ក៏ប៉ុន្តែដោយសារការចាត់វិធានការការពារមិនបានចូលជាធរមាន ស្របតាមកម្មវិធីនៃការលុបបំបាត់ និងកាត់បន្ថយពន្ធរបស់ភាគីដូចមានចែងក្នុងឧបសម្ព័ន្ធ ១ និង ២ ។

១០ - ទោះជាមានបទបញ្ញត្តិនៃមាត្រានេះ គ្មានភាគីណាមួយអាចចាត់វិធានការការពារនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ ទៅលើទំនិញដែលការប្តឹងតវ៉ាកំពុងដំណើរការស្របទៅតាមមាត្រា XIX នៃ GATT ១៩៩៤ និងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកស្តីពីការការពារ ។ នៅពេលភាគីណាមួយមានបំណងអនុវត្តអនុលោមតាមមាត្រា XIX នៃ GATT ១៩៩៤ និងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកស្តីពីការការពារ ការប្តឹងតវ៉ាលើ

ទំនិញ ដែលវិធានការការពារពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ កំពុងដំណើរនឹងត្រូវបញ្ឈប់មុនការប្តឹងតវ៉ាស្របតាម XIX នៃ GATT ១៩៩៤ និងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកស្តីពីការការពារ ។

១១ - រាល់លិខិតទំនាក់ទំនង និងសំណុំឯកសារផ្លូវការដែលបានផ្លាស់ប្តូរក្នុងចំណោមបណ្តាភាគី និងទៅគណៈកម្មការអនុវត្តនូវរាល់ការពាក់ព័ន្ធ វិធានការការពារពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ ត្រូវតែជាលាយល័ក្ខអក្សរ និងត្រូវជាភាសាអង់គ្លេស ។

## មាត្រា ១០
## វិធានការការពារជញ្ជីងទូទាត់

នៅពេលដែលភាគីជួបការលំបាកធ្ងន់ធ្ងរខាងជញ្ជីងទូទាត់ ឬហិរញ្ញវត្ថុក្រៅប្រទេស ឬការគំរាមកំហែងចេញពីនោះ យោងតាមកិច្ចព្រមព្រៀង GATT ឆ្នាំ ១៩៩៤ ភាគីអាចអនុម័តវិធានការរឹតត្បិតលើការនាំចូលដែលរាប់បញ្ចូលទាំងកិច្ចសំរុះសំរួលស្តីពីបទបញ្ញត្តិនៃជញ្ជីងទូទាត់នៃកិច្ចព្រមព្រៀង GATT ឆ្នាំ ១៩៩៤។ នៅក្នុងការអនុម័តវិធានការបែបនេះ ភាគីត្រូវពិគ្រោះជាបន្ទាន់ជាមួយភាគីដទៃទៀត ។

## មាត្រា ១១
## ការលើកលែងជាទូទៅ

គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវបានបកស្រាយដើម្បីរារាំងការអនុម័ត ឬការអនុវត្តន៍ដោយភាគីនូវវិធានការ តែស្ថិតនៅក្រោមការតំរូវថា វិធានការទាំងនោះមិនត្រូវបានអនុវត្តដើម្បីបង្កើតជាការរើសអើងដោយរំលោភ ឬមិនអាចដោះស្រាយបានក្នុងចំណោមភាគីទាំងឡាយ នូវពេលដែលល័ក្ខខ័ណ្ឌដូចគ្នាកើតមានឡើង ឬការរឹតត្បិតដាក់លោកលើពាណិជ្ជកម្មអន្តរជាតិ :

ក- ចាំបាច់សំរាប់ការពារសីលធម៌សាធារណៈ

ខ- ចាំបាច់សំរាប់ការពារសុខភាព និងជីវិតមនុស្ស សត្វ និងរុក្ខជាតិ

គ- ពាក់ព័ន្ធដល់ការនាំចូល និងនាំចេញ មាស ឬប្រាក់ IV

ឃ- ចំបាច់ដើម្បីធានាការគោរពច្បាប់ ឬបទបញ្ជាដែលមិនស្របតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ រាប់បញ្ចូលទាំងច្បាប់ ឬបទបញ្ជាទាក់ទងដល់ការអនុវត្តន៍ច្បាប់ ឬបទបញ្ជាគយ ការអនុវត្តន៍ឯកសិទ្ធិក្រោមកថាខ័ណ្ឌ ៤ នៃមាត្រា ២ និងមាត្រា ១៧ នៃកិច្ចព្រមព្រៀង GATT 1994 ការការពារប៉ាតង់ ពាណិជ្ជសញ្ញា ឬសិទ្ធិចម្លង និងការបង្ការអំពើបំពាន

ង- ទាក់ទងទៅនឹងផលិតផលនៃពលកម្មពន្ធនាគារ

ច- ដាក់ដើម្បីការពារសម្បត្តិជាតិដែលមានតម្លៃខាងបុរាណវិទ្យា ប្រវត្តិសាស្ត្រ និង សិល្បៈ

ឆ- ទាក់ទងដល់ការរក្សាធនធានធម្មជាតិដែលមិនអាចកើតឡើងវិញបាន បើវិធានការបែបនេះ ត្រូវបានចាត់ស្របតាមការរឹតត្បិតលើការប្រើប្រាស់ និងផលិតកម្មក្នុងស្រុក

ជ- ចាត់ស្របតាមកាតព្វកិច្ចនៃកិច្ចព្រមព្រៀងទំនិញអន្តររដ្ឋាភិបាលណាមួយដែលគោរពតាមលក្ខណៈវិនិច្ឆ័យដែលត្រូវបញ្ជូនទៅឱ្យអង្គការពាណិជ្ជកម្មពិភពលោកពិនិត្យ និងមិនត្រូវបានបដិសេធ ឬត្រូវបានបញ្ជូនទៅដោយខ្លួនឯងនឹងមិនត្រូវបានបដិសេធ

ឈ- ទាក់ទងដល់ការរឹតត្បិតការនាំចេញវត្ថុធាតុក្នុងស្រុកចាំបាច់ដើម្បីធានាបរិមាណចាំបាច់នៃវត្ថុធាតុដើមនេះសំរាប់ឧស្សាហកម្មកែច្នៃក្នុងស្រុក ក្នុងរយៈពេលដែលតម្លៃក្នុងស្រុកនៃវត្ថុធាតុដើមនេះត្រូវបានកំណត់ទាបជាងតម្លៃពិភពលោកដែលជាផ្នែកមួយនៃផែនការស្ថេរកម្មរដ្ឋាភិបាលសំរាប់

ដរាបណាការរឹតត្បិតនេះមិនធ្វើឡើងដើម្បីបង្កើនការនាំចេញ ឬការពារឧស្សាហកម្មក្នុងស្រុកនេះ និងមិនប្រាកចាកពីបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះពាក់ព័ន្ធទៅនឹងការមិនរើសអើង

ញ- ចាំបាច់ដល់ការទិញ ឬដល់ការចែកចាយផលិតផលនៃការផ្គត់ផ្គង់មានការខ្វះខាតជាទូទៅ ឬក្នុងស្រុក ដរាបណាវិធានការបែបនោះស្របតាមគោលការណ៍ភាគីទាំងអស់មានសិទ្ធិទៅ និងចំណែកយុត្តិធម៌នៃការផ្គត់ផ្គង់អន្តរជាតិនៃផលិតផលនោះ ហើយវិធានការបែបនេះដែលស្របតាមបទបញ្ញត្តិផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះត្រូវបានបញ្ឈប់នៅពេលដែលល័ក្ខខ័ណ្ឌនៃការចាត់វិធានការលែងមានទៀតហើយ ។

## មាត្រា ១២

## ការលើកលែងខាងសន្តិសុខ

គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវបានបកស្រាយ :៧

ក- ទាមទារឱ្យភាគីណាមួយផ្តល់ពត៌មានដែលការប្រាប់ឱ្យដឹង ត្រូវបានចាត់ទុកថាផ្ទុយទៅនឹងផលប្រយោជន៍សន្តិសុខយ៉ាងសំខាន់

ខ- រារាំងភាគីណាមួយពីការធ្វើសកម្មភាពដែលចាត់ទុកថាចាំបាច់សំរាប់ការពារផលប្រយោជន៍ខាងសន្តិសុខសំខាន់រាប់បញ្ចូលទាំង តែមិនកំណត់ត្រឹម :

១-សកម្មភាពទាក់ទងដល់វត្ថុធាតុបរមាណូ និងវត្ថុធាតុចេញពីនេះ

២- សកម្មភាពទាក់ទងដល់ការជួញដូរអាវុធ គ្រាប់រំសេវ និង ឧបករណ៍សង្គ្រាម និងការជួញដូរទំនិញ និងវត្ថុធាតុផ្សេងទៀតដែលធ្វើឡើងដោយផ្ទាល់ ឬដោយប្រយោលដើម្បីគោលដៅផ្គត់ផ្គង់យោធា

៣-សកម្មភាពធ្វើឡើងដើម្បីការពារហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍សំខាន់ពីការប៉ុនប៉ងដាក់លាក់ធ្វើឱ្យលែងប្រើការបាន ឬធ្វើឱ្យអន់ថយហេដ្ឋារចនាសម្ព័ន្ធនេះ

៤-សកម្មភាពដែលធ្វើនៅពេលសង្គ្រាម ឬក្នុងករណីបន្ទាន់ក្នុងទំនាក់ទំនងជាតិ ឬអន្តរជាតិ

គ - រារាំងភាគីណាមួយពីការធ្វើសកម្មភាពស្របតាមកាតព្វកិច្ចនៃធម្មនុញ្ញសហប្រជាជាតិសំរាប់ការរក្សាសន្តិភាពអន្តរជាតិ និងសន្តិសុខ ។

## មាត្រា ១៣
## រដ្ឋាភិបាលតំបន់ និង មូលដ្ឋាន

ក្នុងការសំរេចកាតព្វកិច្ច និងការសន្យានៃកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗត្រូវធានាការគោរពដោយរដ្ឋាភិបាល និងអាជ្ញាធរតំបន់ និងមូលដ្ឋាននៅក្នុងដែនដីរបស់ខ្លួន ព្រមទាំងការគោរពដោយអង្គភាពមិនមែនរដ្ឋាភិបាលក្នុងការប្រើអំណាចផ្តល់ឱ្យដោយរដ្ឋាភិបាល ឬអាជ្ញាធរកណ្តាល តំបន់ និងមូលដ្ឋាននៅក្នុងដែនដីរបស់ខ្លួន ។

## មាត្រា ១៤
## កិច្ចសំរុះសំរួលស្ថាប័ន

បណ្តាស្ថាប័នដូចមានចែងក្នុងមាត្រា ៥.៣ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ត្រូវត្រួតពិនិត្យ សំរបសំរួល និងពិនិត្យឡើងវិញនៅពេលណាសមស្រប ការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ។

## មាត្រា ១៥

## ការពិនិត្យឡើងវិញ

១- រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងកូរ៉េ ឬតំណាងរបស់ខ្លួនត្រូវជួបជុំគ្នាម្តងនៅក្នុងឆ្នាំនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ បន្ទាប់មកពីរឆ្នាំម្តង ឬផ្សេងពីនេះ តាមការសមស្រប ដើម្បីពិនិត្យឡើងវិញកិច្ចព្រមព្រៀងនេះក្នុងទិសដៅពិតគួរបន្ថែមទៀតនូវវិធានការដើម្បីធ្វើសេរីកម្មពាណិជ្ជកម្មទំនិញព្រមទាំងរៀបចំវិន័យ និងចរចាកិច្ចព្រមព្រៀងអំពីបញ្ហាដូចមានចែងក្នុងមាត្រា ៧ ឬបញ្ហាពាក់ព័ន្ធផ្សេងទៀតទៅតាមការឯកភាពគ្នា ។

២ - ដោយផ្អែកលើបទពិសោធន៍រៀងៗខ្លួននៅក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងនេះ បណ្តាភាគីត្រូវពិនិត្យឡើងវិញទំនិញវេទយិតនៅឆ្នាំ ២០១២ និងក្រោយមកទៀតរៀងរាល់ ៣ឆ្នាំ ម្តង ដើម្បីធ្វើអោយប្រសើរល័ក្ខខ័ណ្ឌនៃការបើកទីផ្សារទំនិញវេទយិត រាប់បញ្ចូលទាំងលទ្ធភាពនៃការបន្ថយថែមទៀតនូវបរិមាណទំនិញវេទយិត និងល័ក្ខខ័ណ្ឌណែនាំប្រព្រឹត្តកម្មអគ្រាពន្ធទៅវិញទៅមកនៃទំនិញដែលភាគីបានដាក់ក្នុងប្រភេទវេទយិត ។

## មាត្រា ១៦

## ឧបសម្ព័ន្ធ និងលិខិតុបករណ៍នាពេលអនាគត

១ - ឧបសម្ព័ន្ធ និងសេចក្តីបន្ថែមទាំងឡាយគឺជាផ្នែកនៃកិច្ចព្រមព្រៀងនេះ ។

២- បណ្តាភាគីអាចអនុម័តលិខិតូបករណ៍នៅពេលខាងមុខ ស្របតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។ ផ្អែកលើចូលជាធរមានរៀងៗខ្លួន លិខិតូបករណ៍ទាំងនេះគឺជាផ្នែកនៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ១៧

## វិវាទជនកម្ម

បទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះអាចកែប្រែតាមរយៈវិសោធនកម្មដែលបានឯកភាពគ្នាទៅវិញទៅមកជាលាយលក្ខណ៍អក្សរដោយបណ្តាភាគី ។

## មាត្រា ១៨

## ទំនាក់ទំនងនៅកិច្ចព្រមព្រៀងផ្សេងទៀត

លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ កិច្ចព្រមព្រៀងនេះ ឬសកម្មភាពណាមួយដែលបានធ្វើក្រោមកិច្ចព្រមព្រៀងនេះ មិនប៉ះពាល់ ឬធ្វើឱ្យមោឃៈសិទ្ធិ និងកាតព្វកិច្ចនៃភាគីក្រោមកិច្ចព្រមព្រៀងនានាដែលមានស្រាប់ ដែលភាគីនោះជាហត្ថលេខី ។

## មាត្រា ១៩

## ការដោះស្រាយវិវាទ

លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ វិវាទពីការបកស្រាយ ការអនុវត្តន៍កិច្ចព្រមព្រៀងនេះត្រូវដោះស្រាយតាមរយៈនីតិវិធី និងយន្តការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយវិវាទនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ។

## មាត្រា ២០

## កន្លែងតម្កល់ទុកឯកសារ

សំរាប់ប្រទេសសមាជិកអាស៊ាន កិច្ចព្រមព្រៀងនេះត្រូវរក្សាទុកដោយអគ្គលេខាធិការអាស៊ាន ដែលត្រូវផ្តល់ច្បាប់បញ្ជាក់ទៅគ្រប់ប្រទេសសមាជិកអាស៊ាន ។

## មាត្រា ២១

## ការចូលជាធរមាន

១- កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាននៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៦ ដរាបណា យ៉ាងហោចណាស់ ប្រទេសសមាជិកអាស៊ានមួយៗ និងកូរ៉េដែលក្នុងចំណោមប្រទេសហត្ថលេខីបានជូនពត៌មាននៅពេលនោះទៅភាគីផ្សេងទៀតទាំងអស់ជាលាយល័ក្ខអក្សរអំពីការបញ្ចប់បែបបទក្នុងស្រុក ។ ក្នុងករណីដែលកិច្ចព្រមព្រៀងនេះមិនអាចចូលជាធរមាននៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៦ កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាននៅថ្ងៃទី ០១ នៃខែទី ០២ បន្ទាប់ពីកាលបរិច្ឆេទខាងដើម ដែលនៅពេលនោះយ៉ាងហោចណាស់ប្រទេសអាស៊ានមួយ និងកូរ៉េបានជូនពត៌មានទៅគ្រប់ភាគីទាំងអស់ផ្សេងទៀតជាលាយល័ក្ខអក្សរអំពីការបញ្ចប់នីតិវិធីក្នុងស្រុក ។

២ - ភាគីត្រូវជូនពត៌មានទៅភាគីផ្សេងទៀតទាំងអស់ជាលាយល័ក្ខអក្សរនៅពេលបញ្ចប់នីតិវិធីក្នុងស្រុកសំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ។

៣- នៅពេលដែលភាគីមិនអាចបញ្ចប់នីតិវិធីក្នុងស្រុកសំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ តាមកាលបរិច្ឆេទកំណត់ក្នុងកថាខ័ណ្ឌទី ១ កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមានសំរាប់ភាគីនោះនៅកាលបរិច្ឆេទនៃការជូនដំណឹងពីការបញ្ចប់នីតិវិធីក្នុងស្រុក ។ ប៉ុន្តែភាគីពាក់ព័ន្ធត្រូវគោរពល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះរាប់បញ្ចូលទាំងការសន្យាថែមទៀត ដែលបានធ្វើឡើងដោយភាគីផ្សេងទៀតក្រោមកិច្ចព្រមព្រៀងនេះ នៅពេលជូនពត៌មាននេះ ហាក់ដូចជាភាគីពាក់ព័ន្ធនេះបានជូនពត៌មានទៅភាគីផ្សេងទៀតជាលាយល័ក្ខអក្សរអំពីការបញ្ចប់នីតិវិធីក្នុងស្រុកមុនកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ។

**ជាសក្ខីភាព** ហត្ថលេខីខាងក្រោមដោយមានការអនុញ្ញាតិស្របច្បាប់បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញនេះ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការទូលំទូលាយរវាងរដ្ឋាភិបាលនៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ ។

ធ្វើនៅកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៥ ជាពីរច្បាប់ជាភាសាអង់គ្លេស ។

សំរាប់រដ្ឋាភិបាលប្រ៊ូណេដារ៉ូសាឡឹម

លឹម ជក សេង

រដ្ឋមន្ត្រីទី២ នៃក្រសួងការបរទេស និងពាណិជ្ជកម្ម

សំរាប់រាជរដ្ឋាភិបាលកម្ពុជា

ចម ប្រសិទ្ធ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូនេស៊ី

ម៉ារី អែលកា ប៉េងជីទូ

រដ្ឋមន្ត្រីពាណិជ្ជកម្ម

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

ណាំ វីយាកេត

រដ្ឋមន្ត្រីឧស្សាហកម្ម និងពាណិជ្ជកម្ម

សំរាប់រដ្ឋាភិបាលម៉ាឡេស៊ី

រ៉ាហ្វីដា អាស៊ីស

រដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិ និង ឧស្សាហកម្ម

សំរាប់រដ្ឋាភិបាលសភាពមីយ៉ាន់ម៉ា

ស៊ូ ចា
រដ្ឋមន្ត្រីក្រសួងផែនការជាតិ និងអភិវឌ្ឍន៍សេដ្ឋកិច្ច

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន

ផីតថឺ បី ហ្វាវិឡា
រដ្ឋមន្ត្រីពាណិជ្ជកម្ម និង ឧស្សាហកម្ម

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋសិង្ហបូរី

លឹម អ៊ុង គៀង
រដ្ឋមន្ត្រីពាណិជ្ជកម្ម និង ឧស្សាហកម្ម

សំរាប់រដ្ឋាភិបាលថៃឡង់ដ៍

សំគិត ចាទូរីពីតាក់
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីពាណិជ្ជកម្ម៧

ង សេខា ធិចបច្ចេកទេស
ាគស្រាវជ្រាវច្បាប់
...៥៨៤...
២១...
ម៉ោង ...

# កិច្ចព្រមព្រៀង
# ស្តីពី
# យន្តការដោះស្រាយវិវាទ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋាភិបាលប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង សាធារណរដ្ឋកូរ៉េ

រដ្ឋាភិបាលនៃប្រ៊ុយណេដារ៉ូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបូរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ

យោងកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋាភិបាលប្រទេសមាជិកនៃសហគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េដែលបានចុះហត្ថលេខានៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៥ និង

យោងប្រការ៥.១ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីការបង្កើតយន្តការ និងនិតិវិធីដោះស្រាយវិវាទ និងកិច្ចព្រមព្រៀងដទៃទៀតដែលមានចែងនៅក្នុងក្របខ័ណ្ឌ

**បានព្រមព្រៀងដូចខាងក្រោមនេះ ÷**

## ប្រការ ១
## និយមន័យ

សំរាប់គោលបំណងនៃកិច្ចព្រមព្រៀង លើកលែងតែកាលៈ ទេសៈតម្រូវផ្សេងពីនេះ ÷

**អាស៊ាន** មានន័យថា សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ដែលរួមមាន ប្រ៊ុយណេដារ៉ូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ។

**បណ្ដាប្រទេសសមាជិកអាស៊ាន** មានន័យថាការរួមបញ្ចូលគ្នានៃប្រទេសប្រ៊ុយណេដារ៉ូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋ សង្គមនិយមវៀតណាម ។

**ប្រទេសដែលជាសមាជិកអាស៊ាន** មានន័យថា ប្រ៊ុយណេដារ៉ូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ។

**ប្រធាន** មានន័យថា សមាជិកនៃសាលាក្ដី បំរើជាប្រធាននៃសាលាក្ដី ។

**ភាគីប្ដឹងតវ៉ា** មានន័យថា បណ្ដាភាគីណាដែលស្នើឱ្យមានការពិគ្រោះ ក្រោមកថាខ័ណ្ឌ ១ នៃប្រការ ៣ ។

**កិច្ចព្រមព្រៀងគ្របដណ្ដប់** មានន័យថា :

ក- កិច្ចព្រមព្រៀងក្របខ័ណ្ឌ

ខ- កិច្ចព្រមព្រៀងស្ដីពីពាណិជ្ជកម្មទំនិញនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ

គ- កិច្ចព្រមព្រៀងនេះ

ឃ-កិច្ចព្រមព្រៀងទាំងឡាយណាដែលបានចរចាបញ្ចប់រវាងភាគីទាំងអស់ដែលអនុលោមទៅតាមបទបញ្ញត្តិពាក់ព័ន្ធនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ លើកលែងតែផ្សេងពីនេះ

**ថ្ងៃ** មានន័យថា ថ្ងៃនៃប្រតិទិនរាប់បញ្ចូលទាំងបំណាច់សប្ដាហ៍ និងថ្ងៃបុណ្យ ។

**កិច្ចព្រមព្រៀងក្របខ័ណ្ឌ** មានន័យថា កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋាភិបាលប្រទេសសមាជិកនៃសហគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ ។

**បណ្តាភាគី** មានន័យថា ការរួមបញ្ចូលប្រទេសសមាជិកអាស៊ាន និងកូរ៉េ ។

**បណ្តាភាគីវិវាទ ឬបណ្តាភាគីដែលវិវាទ** មានន័យថា ភាគីប្តឹងតវ៉ា និងភាគីប្តឹងតវ៉ាប្រឆាំង ។

**ភាគី** មានន័យថា បណ្តាប្រទេសសមាជិកអាស៊ាន ឬកូរ៉េ ។

**ភាគីប្តឹងតវ៉ាប្រឆាំង** មានន័យថា ភាគីទាំងឡាយណាដែលស្នើសុំឱ្យមានការពិគ្រោះដូចដែលមានចែង នៅក្នុងកថាខ័ណ្ឌ ១ ប្រការ ៣ ។

**ភាគីទីបី** មានន័យថា ភាគីដែលក្រៅពីបណ្តាភាគីវិវាទ ដែលមានចែងនៅក្នុងប្រការ ៧ និង

**អង្គការពាណិជ្ជកម្មពិភពលោក** មានន័យថា អង្គការពាណិជ្ជកម្មពិភពលោក

## ប្រការ ២
## ការរាប់បញ្ចូល និងវិសាលភាព

១. កិច្ចព្រមព្រៀងនេះនឹងអនុវត្តដើម្បីជៀងវាង ឬដោះស្រាយភាពវិវាទដែលកើតឡើងរវាងបណ្តាភាគីនៅក្រោមកិច្ចព្រមព្រៀងគ្របដណ្តប់ ។ លើកលែងតែមិនមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ឬកិច្ចព្រមព្រៀងគ្របដណ្តប់ កិច្ចព្រមព្រៀងនេះនឹងអនុវត្តទៅរាល់បណ្តាវិវាទរវាងបណ្តាភាគី ។

២. ភាពវិធាន និងនីតិវិធីនៃកិច្ចព្រមព្រៀងនេះនឹងអនុវត្តចំពោះវិធាន និងនិតិវិធីពិសេស ឬបន្ថែមស្តីពីការដោះស្រាយវិវាទ ។ ភាពរយៈនេះនឹងមានវិវាទរវាងបណ្តាវិធាន និងនីតិវិធីនៃកិច្ចព្រមព្រៀងនេះចំពោះបណ្តាវិធាន និងនីតិវិធី

ពិសេស ឬបន្ថែមស្តីពីការដោះស្រាយវិវាទដែលមានចែងក្នុងកិច្ចព្រមព្រៀងគ្របដណ្តប់ ។ បណ្តាវិវាទដែលពាក់ព័ន្ធទៅនឹងបណ្តាវិធាន និងនីតិវិធីដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងគ្របដណ្តប់ច្រើនជាងមួយ ប្រសិនបើមានវិវាទទៅនឹងបណ្តាវិធាន និងនីតិវិធីពិសេស ឬបន្ថែម ប្រធាននៃសាលាក្តីត្រូវពិគ្រោះជាមួយបណ្តាភាគីវិវាទដោយកំណត់ពីរបណ្តាវិធាន និងនីតិវិធីក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីការស្នើដោយភាគីវិវាទណាមួយ ។

៣. រាល់បទបញ្ញត្តិនៃកិច្ចព្រមព្រៀងត្រូវបានឱ្យប្រើប្រាស់ចំពោះវិធានការដែលប៉ះពាល់ដល់ការគោរពកិច្ចព្រមព្រៀងគ្របដណ្តប់ដែលមាននៅក្នុងដែនដីនៃភាគីដោយ :

ក- រដ្ឋបាលកណ្តាល តំបន់ ឬ រដ្ឋាបាលនិងអជ្ញាធរផ្ទៃក្នុង ឬ

ខ- ស្ថាប័នក្រៅរដ្ឋាភិបាលដែលផ្តល់សិទ្ធិដោយរដ្ឋបាលកណ្តាល តំបន់ និងរដ្ឋបាល និងអជ្ញាធរ

៤. ក្រោមលក្ខខណ្ឌនៃកថាខ័ណ្ឌ ៥ គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងអាចធ្វើឱ្យខូចខាតសិទ្ធិណាមួយរបស់បណ្តាភាគីដើម្បីដំណើរការនីតិវិធីដោះស្រាយវិវាទ ដែលអាចរកបានក្រោមសិទ្ធិសញ្ញាណាមួយផ្សេងទៀតដែលបណ្តាភាគីបានចូលរួម ។

៥. នៅពេលចាប់ផ្តើមបណ្តឹងដោះស្រាយវិវាទក្រោមកិច្ចព្រមព្រៀងនេះឬក្រោមសិទ្ធិសញ្ញាផ្សេងណាមួយទៀតដែលបណ្តាភាគីជម្លោះបានចូលរួមអំពីសិទ្ធិ ឬកាតព្វកិច្ចពិសេសនៃបណ្តាភាគីទាំងអស់ដែលកើតមានឡើងក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌមានសិទ្ធិសញ្ញាផ្សេងទៀត វេទិកាដែលបានជ្រើសរើសដោយភាគីប្តឹងតវ៉ានឹងត្រូវប្រើប្រាស់ ។

៦. សំរាប់គោលបំណងនៃកថាខ័ណ្ឌ ៤ និង ៥ ភាគីប្តឹងតវ៉ានឹងត្រូវបានចាត់ទុកថាបានជ្រើសរើសវេទិកាណាមួយហើយនៅពេលដែលភាគីនោះបានសំណូមពរឱ្យបង្កើត ឬបញ្ជូនវិវាទទៅឱ្យក្រុមដោះស្រាយវិវាទ ឬសាលាក្តីអនុលោមតាមកិច្ចព្រមព្រៀងនេះ ឬកិច្ចព្រមព្រៀងណាមួយផ្សេងទៀតដែលបណ្តាភាគីវិវាទបានចូលរួម ។

## **ប្រការ ៣**
## **ការពិគ្រោះ**

១. ភាគីប្តឹងតវ៉ាប្រឆាំងត្រូវផ្តល់ការពិចារណាដ៏សមរម្យ និងឱកាសគ្រប់គ្រាន់សំរាប់ការពិគ្រោះចំពោះ សំណូមពរពិគ្រោះដែលបានលើកឡើងដោយភាគីប្តឹងតវ៉ាអំពីបញ្ហាអ្វីមួយ ដែលអាចប៉ះពាល់ដល់ការ បកស្រាយការអនុវត្តន៍នៃ

កិច្ចព្រមព្រៀងគ្របដណ្ដប់ ហើយនៅពេលណាដែលភាគីប្ដឹងតវ៉ាពិចារណាថា ÷

ក- វិធានការដែលភាគីប្ដឹងតវ៉ាប្រឆាំងមិនសមស្របទៅនឹងកាតព្វកិច្ចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងគ្របដណ្ដប់ឬ

ខ- ភាគីប្ដឹងតវ៉ាប្រឆាំងមិនបានបំពេញទៅតាមកាតព្វកិច្ចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងគ្របដណ្ដប់។

រាល់លទ្ធផលដែលប៉ះពាល់ដល់ផលប្រយោជន៍នៃភាគីប្ដឹងតវ៉ានៅក្រោមកិច្ចព្រមព្រៀងគ្របដណ្ដប់ ឬឧបសគ្គទៅនឹងគោលដៅនៃកិច្ចព្រមព្រៀងគ្របដណ្ដប់។

២. សំណូមពរណាមួយសំរាប់ការពិគ្រោះ នឹងត្រូវស្នើឡើងជាលាយល័ក្ខអក្សរដែលត្រូវមានវិធានការជាក់លាក់ចំពោះបញ្ហា និងមានមូលដ្ឋានច្បាប់ស្របទៅតាមស្ថានភាពជាក់ស្ដែង (រាប់បញ្ចូលទាំងរាល់បទបញ្ញត្តិនៃកិច្ចព្រមព្រៀងគ្របដណ្ដប់ដែលត្រូវចោទថាបានរំលោភទៅនឹងបទបញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀត) នៃការប្ដឹងតវ៉ា។ ភាគីប្ដឹងតវ៉ាត្រូវបញ្ជូនសំណូមពរទៅអោយភាគីប្ដឹងតវ៉ាប្រឆាំង ហើយនិងបណ្ដាភាគីដែលសេសសល់។ នៅពេលបានទទួលភាគីប្ដឹងតវ៉ាប្រឆាំងត្រូវប្រាប់ឱ្យដឹងពីការបានទទួលសំណូមពរនេះទៅភាគីប្ដឹងតវ៉ា និងបណ្ដាភាគីដែលសេសសល់ព្រមពេលជាមួយគ្នា។

៣. បើសិនជាសំណូមពរពិគ្រោះត្រូវបានធ្វើឡើង ភាគីប្ដឹងតវ៉ាប្រឆាំងត្រូវឆ្លើយទៅនឹងសំណូមពរនេះក្នុង រយៈពេល ៧ ថ្ងៃក្រោយកាលបរិច្ឆេទនៃការទទួល ហើយត្រូវចាប់ផ្ដើមការពិគ្រោះដោយស្មោះត្រង់ក្នុងរយៈពេលមិនលើសពី ៣០ថ្ងៃក្រោយកាលបរិច្ឆេទនៃការទទួលសំណូមពរ ដើម្បីឈានទៅរកដំណោះស្រាយមួយដែលពេញចិត្តទាំងសងខាង។ បើសិនជាភាគីប្ដឹងតវ៉ាប្រឆាំងមិនឆ្លើយតបក្នុងរយៈពេល ៧ថ្ងៃ ដូចដែលបានចែងខាងលើ ឬមិនបានចាប់ផ្ដើមពិគ្រោះក្នុងរយៈពេល ៣០ថ្ងៃ ដូចចែងខាងលើ ភាគីប្ដឹងតវ៉ាអាចបន្តធ្វើដោយត្រង់ទៅរកសំណើបង្កើតសាលាក្ដីជំនុំជំរះក្រោមប្រការ ៥។

៤. បណ្ដាភាគីវិវាទត្រូវខិតខំដើម្បីឈានដល់ដំណោះស្រាយពេញចិត្តទៅវិញទៅមកនៃបញ្ហាណាក់ដោយតាមរយៈការពិគ្រោះក្រោមប្រការនេះ។ ចំពោះបញ្ហានេះបណ្ដាភាគីវិវាទត្រូវ ÷

ក- ផ្ដល់ពតិមានគ្រប់គ្រាន់ដើម្បីជួយដល់ការពិនិត្យពេញលេញឱ្យដឹងពីវិធានការ ដែលអាចប៉ះពាល់ដល់ប្រតិ-បត្តិការនៃកិច្ចព្រមព្រៀងគ្របដណ្ដប់ និង

ខ- ចាត់ទុកជាការសម្ងាត់នូវពត៌មានណាមួយដែលបានផ្លាស់ប្តូរនៅពេលពិគ្រោះដែលភាគីវិវាទផ្សេងទៀតចាត់ទុកជាការសម្ងាត់។

៥. ការពិគ្រោះជាការសម្ងាត់ និងមិនប៉ះពាល់ដល់សិទ្ធិរបស់ភាគីណាមួយក្នុងបណ្តឹងផ្សេងទៀត ឬបណ្តឹងបន្តណាមួយក្រោមកិច្ចព្រមព្រៀងនេះ ឬបណ្តឹងផ្សេងទៀតមុនពេលវេទិកាជ្រើសរើសដោយបណ្តាភាគី។ បណ្តាភាគីត្រូវផ្តល់ពត៌មានស្តីពីលទ្ធផលនៃការពិគ្រោះ។

៦. ក្នុងករណីបន្ទាន់រាប់បញ្ចូលទាំងករណីដែលពាក់ព័ន្ធដល់ផលិតផលឆាប់ស្អុយរលួយ បណ្តាភាគីវិវាទត្រូវចាប់ផ្តើមពិគ្រោះក្នុងរយៈពេលមិនលើសពី ១០ថ្ងៃ ក្រោយកាលបរិច្ឆេទ នៃការទទួលសំណូមពរដោយភាគីប្តឹងតវ៉ា។ បើសិនជាការពិគ្រោះខកខានមិនបានដោះស្រាយវិវាទក្នុងរយៈពេល ២០ថ្ងៃ ក្រោយកាលបរិច្ឆេទទទួលសំណូមពរដោយភាគីប្តឹងតវ៉ាប្រឆាំង ភាគីប្តឹងតវ៉ាអាចបន្តធ្វើដោយត្រង់ទៅរកការបង្កើតសាលាក្តីក្រោមប្រការ ៥។

៧. ក្នុងករណីបន្ទាន់ រាប់បញ្ចូលទាំងករណីនៃផលិតផលឆាប់ស្អុយរលួយ បណ្តាភាគីនៃវិវាទ និងសាលាក្តីត្រូវធ្វើការប្រឹងប្រែងពន្លឿនបណ្តឹងអោយបានលឿនបំផុត។

## ប្រការ ៤
## ការិយាល័យទំនាក់ទំនង ស្រុះស្រួល និងសម្រុះសម្រួល

១- ការិយាល័យទំនាក់ទំនង ស្រុះស្រួល និងសម្រុះសម្រួលគឺជាទីកន្លែងទទួលរ៉ាប់រងនូវរាល់នីតិវិធី ប្រសិនបើមានការព្រមព្រៀងពីបណ្តាភាគីវិវាទ។

២. ការិយាល័យទំនាក់ទំនង ស្រុះស្រួល និងសម្រុះសម្រួលអាចស្នើដោយភាគីវិវាទណាមួយ នៅពេលណាមួយក៏បាន។ គេអាចចាប់ផ្តើមនៅពេលណាមួយហើយបញ្ចប់ដោយបណ្តាភាគីវិវាទណាមួយនៅពេលណាមួយក៏បាន។

៣. ប្រសិនបើបណ្តាភាគីវិវាទឯកភាព ទម្រង់ការនៃការិយាល័យទំនាក់ទំនង ស្រុះស្រួល និងសម្រុះសម្រួលអាចបន្តនៅចំពោះមុខបុគ្គលណាម្នាក់ ឬស្ថាប័នណាមួយនៅពេលដំណាលគ្នាទៅនឹងទម្រង់ការវិវាទសំរាប់ដោះស្រាយមុនពេល

បង្កើតសាលាក្តីក្រោមប្រការ ៥ ។

៤. ទម្រង់ការនៃការិយាល័យទំនាក់ទំនង ស្រុះស្រួល និងសម្រុះសម្រួល និងជំហរប្រកាន់យកដោយបណ្តាភាគីវិវាទក្នុងរយៈពេលបណ្តឹងត្រូវតែជាការសម្ងាត់ និងមិនប៉ះពាល់ដល់សិទ្ធិនៃភាគីណាមួយក្នុងទម្រង់ការបន្ត ឬផ្សេងទៀតដែលនៅក្រោមកិច្ចព្រមព្រៀងនេះ និងទម្រង់ដទៃទៀតមុនពេលដែលវេទិកាត្រូវបានជ្រើសរើសដោយបណ្តាភាគី ។

## ប្រការ ៥
## ការបង្កើតសាលាក្តី

១. បើសិនជាការពិគ្រោះដូចបានចែងក្នុងប្រការ៣ ខកខានមិនបានដោះស្រាយវិវាទក្នុងរយៈពេល ៦០ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការទទួលសំណូមពរសំរាប់ការពិគ្រោះ ឬក្នុងរយៈពេល ២០ថ្ងៃ ក្រោយកាលបរិច្ឆេទខាងលើ ក្នុងករណីបន្ទាន់រាប់បញ្ចូលទាំងករណីទំនិញងាយស្រួលរលួយ ភាគីប្តឹងតវ៉ាអាចលើកសំណូមពរជាលាយល័ក្ខអក្សរទៅភាគីដែលត្រូវប្តឹងតវ៉ាប្រឆាំងដើម្បីបង្កើតសាលាក្តី ។ ច្បាប់ចម្លងនៃសំណូមពរនេះត្រូវផ្ញើផងដែរទៅបណ្តាភាគីដែលនៅសល់ ។

២. សំណូមពរឱ្យបង្កើតសាលាក្តីត្រូវផ្តល់មូលហេតុរាប់បញ្ចូលទាំងអត្តសញ្ញាណកម្មនៃ ÷

ក- វិធានការជាក់លាក់ចំពោះបញ្ហា និង

ខ- ភាពជាក់ស្តែង និងមូលដ្ឋានច្បាប់ ( រាប់បញ្ចូលទាំងបទបញ្ញត្តិនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌដែលត្រូវបានចោទថាបានបំពាន ឬបទបញ្ញត្តិពាក់ពន្ធ័ផ្សេងទៀត) សំរាប់ការតវ៉ាគ្រប់គ្រាន់ដើម្បីបង្ហាញបញ្ហាអោយបានច្បាស់លាស់ ។

៣- នៅពេលដែលទទួលបានសំណូមពរ សាលាក្តីត្រូវតែបង្កើត ។

៤- លើកលែងតែមានការឯកភាពពីបណ្តាភាគីវិវាទ សាលាក្តីត្រូវតែបង្កើត និងប្រតិបត្តិទៅតាមមុខងារដែលមាននៅក្នុងបណ្តាបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ និងឧបសម្ព័ន្ធស្តីពីវិធាន និងនីតិវិធីសំរាប់ទម្រង់ការសាលាក្តី ។

៥. នៅពេលដែលភាគីតវ៉ាច្រើនជាងមួយ សំណូមឱ្យបង្កើតសាលាក្តីពាក់ព័ន្ធដល់រឿងដូចគ្នា សាលាក្តីតែមួយអាចចាត់តាំងឡើងដោយបណ្តាភាគីពាក់ព័ន្ធនៅពេលដែលអាចធ្វើទៅបានដើម្បីដោះស្រាយបញ្ហាដោយគិតគូរដល់សិទ្ធិរៀងៗខ្លួន។

៦. នៅពេលដែលសាលាក្តីតែមួយត្រូវបានបង្កើតក្រោមកថាខ័ណ្ឌ ៥ សាលាក្តីនោះត្រូវរៀបចំការពិនិត្យ និងបង្ហាញលទ្ធផលទៅរាល់បណ្តាភាគីវិវាទ ដោយគោរពទៅតាមសិទ្ធិដែលពួកគេអាចទទួលបានដោយឱ្យសាលាក្តីដោយឡែកពិនិត្យបញ្ហាតែមួយនេះ។ ប្រសិនបើមានសំណូមពរដោយភាគីវិវាទណាមួយ សាលាក្តីអាចចេញរបាយការណ៍ដោយឡែកអំពីវិវាទ ពាក់ព័ន្ធនៅក្នុងករណីដែលមានពេលវេលាអនុញ្ញាតិគ្រប់គ្រាន់។ ការស្នើសុំជាលាយល័ក្ខអក្សរដោយបណ្តាភាគីវិវាទត្រូវអាចរកបានដោយបណ្តាភាគីផ្សេងទៀត ហើយភាគីនីមួយៗនៃវិវាទមានសិទ្ធិមានវត្តមាននៅពេលភាគីណាមួយនៃភាគីផ្សេងទៀតនៃវិវាទដូចគ្នាបង្ហាញទស្សនៈរបស់ខ្លួនទៅឱ្យសាលាក្តី។

៧. នៅពេលដែលសាលាក្តីច្រើនជាងមួយត្រូវបានបង្កើតដើម្បីពិនិត្យបញ្ហាដូចគ្នាក្នុងកំរិតមួយជាអតិបរិមា ដែលអាចធ្វើទៅបាន បណ្តាភាគីពាក់ព័ន្ធត្រូវចាត់តាំងអាជ្ញាកណ្តាលដូចគ្នាដើម្បីបំរើសាលាក្តីដោយឡែកនីមួយៗ ហើយកាលវិភាគនៃទម្រង់ការរបស់សាលាក្តីដោយឡែកនីមួយៗត្រូវតែស៊ីចង្វាក់គ្នា។

## ប្រការ ៦
## សមាសភាពសាលាក្តី

១. លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ ឬបណ្តាភាគីនៃវិវាទឯកភាព សាលាក្តីត្រូវមានសមាជិកចំនួន ៣ រូប។

២. ភាគីវិវាទនីមួយៗត្រូវចាត់តាំងសមាជិកម្នាក់ទៅសាលាក្តីក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានសំណូមពរស្របតាមប្រការ ៥។ ប្រសិនបើភាគីវិវាទណាមួយខកខានមិនបានចាត់តាំងអាជ្ញាកណ្តាល ទៅសាលាក្តីនៅក្នុងរយៈពេលនោះទេ អាជ្ញាកណ្តាលដែលចាត់តាំងដោយភាគីផ្សេងទៀតនៃវិវាទត្រូវធ្វើជាអាជ្ញាកណ្តាលតែមួយនៃសាលាក្តីដូចដែលមានចែងនៅក្នុងកថាខ័ណ្ឌ ១។[៧]

៣. បណ្តាភាគីវិវាទត្រូវខិតខំឯកភាពគ្នាលើអាជ្ញាកណ្តាលបន្ថែមដែលត្រូវធ្វើជាប្រធាននៃសាលាក្តីក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយបានតែងតាំងជាសមាជិកទី ២។ ប្រសិនបើភាគីវិវាទមិនមានការឯកភាពពីប្រធានអាជ្ញាកណ្តាលនៅក្នុងរយៈពេលនោះទេ ប្រធានអាជ្ញាកណ្តាលចុងក្រោយត្រូវតែបានតែងតាំងស្របតាមកថាខ័ណ្ឌ ២ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ថែម។ ប្រសិនបើភាគីវិវាទខកខានមិនបានតែងតាំងប្រធានសាលាក្តីទៅតាមពេលវេលាខាងលើត្រូវសំណូមពរឱ្យអគ្គនាយកនៃអង្គការពាណិជ្ជកម្មពិភពលោកចាត់តាំងប្រធានក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីថ្ងៃដែលទទួលបានសំណូមពរ។ ក្នុងករណីដែលអគ្គនាយកនៃអង្គការពាណិជ្ជកម្មពិភពលោកជាជនជាតិនៃបណ្តាភាគីវិវាទណាមួយ អគ្គនាយករង ឬមន្ត្រីបន្ទាប់តាមភាពចាស់វស្សាដែលមិនមែនជាជនជាតិនៃភាគីទាំងពីរនៃវិវាទត្រូវបានសំណូមពរឱ្យចាត់តាំងប្រធានសាលាក្តី។

៤. កាលបរិច្ឆេទនៃការបង្កើតសាលាក្តីត្រូវតែជាកាលបរិច្ឆេទដែលប្រធានសាលាក្តីត្រូវបានចាត់តាំងស្របតាមកថាខ័ណ្ឌ ៣ ឬថ្ងៃទី ៣០ ក្រោយការទទួលសំណូមពរស្របតាមប្រការ ៥ នៅពេលដែលអាជ្ញាកណ្តាលតែមួយគត់នៃសាលាក្តីអាចរកបាន។

៥. បើអាជ្ញាកណ្តាលចាត់តាំងហើយស្របតាមប្រការនេះសុំលាលែង ឬគ្មានសមត្ថភាពបំពេញមុខងារ អាជ្ញាកណ្តាលស្នងត្រូវបានចាត់តាំងតាមរបៀបដូចគ្នា ដូចបានរៀបរាប់សំរាប់ការចាត់តាំងអាជ្ញាកណ្តាលដើម ហើយអ្នកស្នងនេះត្រូវមានអំណាច និងកាតព្វកិច្ចដូចអាជ្ញាកណ្តាលដើមដែរ។ ការងាររបស់សាលាក្តីត្រូវព្យួររហូតទាល់តែមានការចាត់តាំងអាជ្ញាកណ្តាលស្នង។

៦. បុគ្គលណាក៏ដោយដែលត្រូវចាត់តាំងជាសមាជិក ឬប្រធាននៃសាលាក្តីត្រូវមានជំនាញ ឬបទពិសោធន៍ខាងច្បាប់ដូចជាច្បាប់ពាណិជ្ជកម្មអន្តរជាតិ បញ្ហាផ្សេងទៀតដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងគ្របដណ្តប់ ឬការដោះស្រាយវិវាទកើតចេញមកពីកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ។ សមាជិកត្រូវបានជ្រើសរើសយ៉ាងតឹងតែងដោយផ្អែកទៅលើភាពមិនលំអៀង ការទទួលខុសត្រូវ ការវិនិច្ឆ័យត្រឹមត្រូវនិងឯករាជ្យ និងភាពនឹងនរបស់ខ្លួនបុគ្គលនោះក្នុងរយៈពេលទម្រង់ការសាលាក្តី។ ប្រសិនបើភាគីវិវាទយល់ឃើញថា សមាជិករូបនោះបានបំពានទៅនឹងមូលដ្ឋានដែលចែងខាងលើ បណ្តាភាគីវិវាទត្រូវតែពិគ្រោះនឹងបើមានការឯកភាព សមាជិកនោះត្រូវដកចេញ និងបំពេញដោយសមាជិកថ្មីស្របទៅតាមប្រការនេះ។ បន្ថែមពីលើប្រធានសាលាក្តីមិនត្រូវជាជនជាតិនៃភាគីវិវាទណាមួយ និងមិនត្រូវមានកន្លែងស្នាក់នៅជាប់លាប់ក្នុងដែនដី ឬត្រូវបានជួលដោយភាគីវិវាទណាមួយ។៧

៧.    នៅពេលសាលាក្តីដើមត្រូវបានតម្រូវសំរាប់រឿងក្តីដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះប៉ុន្តែមិនអាចវិនិច្ឆ័យរឿងក្តីដោយមូលហេតុណាមួយ សាលាក្តីថ្មីត្រូវតែបង្កើតឡើងក្រោមប្រការនេះទៅតាមពេលវេលាដូចគ្នា ដែលបានកំណត់។

## ប្រការ ៧
## ភាគីទី ៣

១.   ភាគីណាមួយដែលមានផលប្រយោជន៍ធំដុំក្នុងវិវាទនៅចំពោះមុខសាលាក្តី   និងបានជូនពត៌មានពីការទាក់ទងនឹងផលប្រយោជន៍របស់ខ្លួនជាលាយលក្ខ័អក្សរទៅឱ្យបណ្តាភាគីវិវាទ   និងភាគីនៅសល់ត្រូវមានឱកាសដាក់ជូនពិនិត្យជាលាយលក្ខ័អក្សរទៅសាលាក្តី។ ការដាក់ជូនពិនិត្យនេះត្រូវផ្តល់ទៅឱ្យបណ្តាភាគីវិវាទ   និងត្រូវបង្ហាញឱ្យឃើញនៅក្នុងរបាយការណ៍នៃសាលាក្តី។

២.  ភាគីទី ៣ ត្រូវបានទទួលការដាក់ឱ្យពិនិត្យពីបណ្តាភាគីវិវាទចាប់តាំងពីកិច្ចប្រជុំលើកទីមួយនៃសាលាក្តី។

៣.    បើភាគីទីពាចាត់ទុកថា  វិធានការដែលជាកម្មវត្ថុនៃទំរង់ការសាលាក្តីដែលមានរួចហើយនោះធ្វើឱ្យគ្មានតម្លៃ  ឬបន្ថយផលប្រយោជន៍ក្រោមកិច្ចព្រមព្រៀងគ្របដណ្តប់ភាគីនោះអាចសើរើទៅរកនិតិវិធីដោះស្រាយវិវាទធម្មតាក្រោមកិច្ចព្រមព្រៀងនេះ។

## ប្រការ ៨
## ការព្យួរ និង ការបញ្ចប់ទម្រង់ការ

១. នៅទីណាដែលបណ្តាភាគីវិវាទឯកភាព សាលាក្តីអាចព្យួរការងាររបស់ខ្លួននៅពេលណាក៏បានសំរាប់រយៈ ពេលមិនលើសពីដប់ពីរ   (១២)ខែ   ចាប់ពីកាលបរិច្ឆេទនៃការឯកភាពនេះ។   តាមសំណូមពររបស់ភាគីណាមួយនៃវិវាទទម្រង់ការការសាលាក្តីត្រូវចាប់ផ្តើមឡើងវិញក្រោយការព្យួរនេះ។ បើការងារនៃសាលាក្តីត្រូវបានព្យួរ ច្រើនជាងដប់ពី (១២)ខែ អំណាចនៃការបង្កើតសាលាក្តីនឹងត្រូវអស់  លើកលែងតែភាគីពាក់ព័ន្ធឯកភាពផ្សេងពីនេះ។

២. បណ្តាភាគីវិវាទអាចឯកភាពបញ្ចប់ទម្រង់ការសាលាក្តីនៅពេលណាមួយក៏បានមុនការបញ្ចេញរបាយការណ៍ចុងក្រោយក្នុងករណីដែលដំណោះស្រាយពេញចិត្តទៅវិញទៅមកត្រូវបានរកឃើញ ។

៣. មុនសាលាក្តីធ្វើការសំរេច សាលាក្តីអាចស្នើដល់បណ្តាភាគីវិវាទនៅគ្រប់ដំណាក់កាលណាមួយនៃទម្រង់ការថាវិវាទបានដោះស្រាយដោយមេត្រីភាព ។

## ប្រការ ៩
## មុខងាររបស់សាលាក្តី

១. មុខងាររបស់សាលាក្តី គឺការវាយតម្លៃដោយមិនលំអៀងនៃវិវាទរាប់បញ្ចូលទាំងការពិនិត្យដំណើរហេតុនៃករណី និងភាពអាចអនុវត្តបានអនុលោមទៅតាមកិច្ចព្រមព្រៀងគ្របដណ្តប់ពាក់ព័ន្ធ ។ នៅទីណាដែលសាលាក្តីសំរេចថាវិធានការមិនស្របតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងគ្របដណ្តប់ សាលាក្តីត្រូវផ្តល់អនុសាសន៍ឱ្យភាគីប្តឹងតវ៉ាប្រឆាំងត្រូវតែទទួលយកវិធានការនោះស្របតាមបទបញ្ញត្តិ ។ បន្ថែមពីលើអនុសាសន៍របស់ខ្លួន សាលាក្តីអាចស្នើវិធីសាស្ត្រដែលភាគីប្តឹងតវ៉ាប្រឆាំងអាចអនុវត្តអនុសាសន៍នោះបាន ។ សាលាក្តីត្រូវពិគ្រោះជាប្រចាំជាមួយបណ្តាភាគីវិវាទ និងផ្តល់ឱកាសសមរម្យសំរាប់ការអភិវឌ្ឍន៍ដំណោះស្រាយពេញចិត្តទៅវិញទៅមក ។ សាលាក្តីត្រូវបកស្រាយរាល់បទបញ្ញត្តិនៅក្នុងកិច្ចព្រមព្រៀងគ្របដណ្តប់ស្របទៅតាមទំលាប់នៃការបកស្រាយជាសាធារណៈនៃច្បាប់អន្តរជាតិ ។ នៅក្នុងរកឃើញ និងអនុសាសន៍របស់ខ្លួន សាលាក្តីពុំអាចបន្ថែមឬបន្ថយសិទ្ធិ និងកាតព្វកិច្ចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងគ្របដណ្តប់ ។

## ប្រការ ១០
## ទម្រង់ការរបស់សាលាក្តី

១. វិធានការ និងនីតិវិធីពាក់ព័ន្ធដល់ទម្រង់ការចំពោះមុខសាលាក្តីដូចចែងនៅក្នុងឧបសម្ព័ន្ធស្តីពីវិធានការនិងនីតិវិធីសំរាប់ទម្រង់ការសាលាក្តីត្រូវអនុវត្តលើកលែងតែបណ្តាភាគីវិវាទឯកភាពផ្សេងពីនេះ ។ ក្រោយពីពិគ្រោះជាមួយបណ្តាភាគីវិវាទសាលាក្តីអាចអនុម័តវិធានការ និងនីតិវិធីបន្ថែមដែលខុសពីឧបសម្ព័ន្ធស្តីពីវិធានការ និងនីតិវិធីសំរាប់ទម្រង់ការសាលាក្តី ។w

២. នៅក្នុងករណីណាក៏ដោយ ទម្រង់ការសាលាក្តីត្រូវតែអនុលោមទៅតាមគោលការណ៍ខាងក្រោម ÷

ក-មានសិទ្ធិយ៉ាងហោចណាស់ម្តងស្តាប់មុនពេលសាលាក្តីចាប់ផ្តើម

ខ- ផ្តល់ឱកាសឱ្យភាគីវិវាទនិមួយៗផ្តល់គំនិតផ្តួចផ្តើម និងគំនិតជំទាស់

គ-ផ្តល់ឱកាសយ៉ាងសមរម្យចំពោះភាគីវិវាទដើម្បីប្រគល់ជូននូវអនុសាសន៍ស្តីពីរបាយការណ៍បណ្តោះអាសន្ន ដែលបានបកស្រាយទៅតាមប្រការ ១១ និង

ឃ- ការពារពត៌មានសម្ងាត់

៣. សាលាក្តីត្រូវជួបរាល់ពេលប្រជុំ។ បណ្តាភាគីវិវាទត្រូវមានវត្តមាននៅពេលការអញ្ជើញពីសាលាក្តីដើម្បីបង្ហាញខ្លួនមុនពេលសាលាក្តី។

## ប្រការ ១១

## របាយការណ៍បណ្តោះអាសន្ន

១. លើកលែងតែមានការឯកភាពពីភាគីវិវាទ សាលាក្តីត្រូវរាយការណ៍ជាមូលដ្ឋានស្តីពីបទបញ្ញត្តិពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងគ្របដណ្តប់ស្តីពីការយល់ព្រម និងជំទាស់ពីបណ្តាភាគីវិវាទ និងរាល់ពត៌មានពីមុនមកដោយអនុលោមទៅតាមប្រការ ១៣។

២. លើកលែងតែមានការឯកភាពពីភាគីវិវាទ សាលាក្តីក្នុងរយៈពេលកៅសិប (៩០) ថ្ងៃ ក្រោយពីការបង្កើតសាលាក្តីត្រូវបង្ហាញជូនភាគីវិវាទនូវរបាយការណ៍បណ្តោះអាសន្នដែលមាន :

ក- ស្ថានភាពជាក់ស្តែងពីច្បាប់ និងមូលហេតុនៃវិវាទព្រមពេលជាមួយគ្នា

ខ- បញ្ជាក់ពីការបកស្រាយការអនុវត្តន៍ ឬបែបបទដែលពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងគ្របដណ្តប់ ឬវិធានការនៃបញ្ហាដែលខុសពីកាតព្វកិច្ចនៃភាគីប្តឹងតវ៉ាប្រឆាំងក្រោមកិច្ចព្រមព្រៀងគ្របដណ្តប់ដែលពាក់ព័ន្ធ ឬភាគីប្តឹងតវ៉ាប្រឆាំងខកខានមិនបានបំពេញកាតព្វកិច្ចនៅក្រោមកិច្ចព្រមព្រៀងគ្របដណ្តប់ ឬវិធានការនៃបញ្ហាដែលបណ្តាលឱ្យបាត់ទុកជាមោឃៈ ឬមិនហុចផលប្រយោជន៍ដល់ភាគីប្តឹងតវ៉ានៅក្រោមកិច្ចព្រមព្រៀងគ្របដណ្តប់ ឬការសំរេចដែលនាំមកនូវគ្រោះថ្នាក់ដល់គោលបំណងនៃកិច្ចព្រមព្រៀងគ្របដណ្តប់ ឬការស្នើការសំរេចសំរាប់ជាភស្តុតាង ។៧

គ- នៅពេលដែលការកំណត់វិធានការមិនសមស្របទៅនឹងការតព្វកិច្ចនៅក្រោមកិច្ចព្រមព្រៀងគ្រប់ដណ្ដប់ រាល់អនុសាសន៍ទាំងឡាយណាដែលមានហើយអនុលោមទៅតាមកិច្ចព្រមព្រៀងគ្រប់ដណ្ដប់ និងការណែនាំនោះ វាជាវិធីសាស្ត្រដែលភាគីប្ដឹងតវ៉ាប្រឆាំងអាចអនុវត្តបាន ។

៣. នៅពេលដែលសាលាក្ដីពិចារណាឃើញថា របាយការណ៍បណ្ដោះអាសន្ននេះមិនអាចបង្ហាញក្នុងរយៈពេលដែលមានចែងនៅក្នុងកថាខ័ណ្ឌ ២ សាលាក្ដីត្រូវជូនពត៌មានទៅភាគីវិវាទជាលាយល័ក្ខអក្សរស្ដីពីមូលហេតុក្នុងការយឺតយ៉ាវ និងប្រាប់ពីពេលវេលាដែលអាចបង្ហាញរបាយការណ៍បណ្ដោះអាសន្ននោះបាន ។

៤. បណ្ដាភាគីវិវាទអាចផ្ដល់ជូនអនុសាសន៍ជាលាយល័ក្ខអក្សរស្ដីពីរបាយការណ៍បណ្ដោះអាសន្នក្នុងរយៈពេលដប់បួន (១៤) ថ្ងៃ ចាប់ពីថ្ងៃបង្ហាញរបាយការណ៍ ។

៥. ក្នុងករណីដែលបានទទួអនុសាសន៍ជាលាយល័ក្ខអក្សរដែលមានចែងនៅក្នុងកថាខ័ណ្ឌ ៤ ពីបណ្ដាភាគីវិវាទទោះបីជាទៅតាមការស្នើដោយភាគីវិវាទ ឬទៅតាមគនិតផ្ទាល់ សាលាក្ដីត្រូវពិចារណារបាយការណ៍ឡើងវិញ និងត្រូវធ្វើការពិនិត្យពិចារណាបន្ថែម ។

## ប្រការ ១២
## របាយការណ៍ចុងក្រោយ

១. សាលាក្ដីត្រូវបង្ហាញរបាយការណ៍ចុងក្រោយទៅបណ្ដាភាគីវិវាទក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីការបង្ហាញរបាយការណ៍បណ្ដោះអាសន្ន ។

២. សាលាក្ដីត្រូវបង្ហាញពីរបាយការណ៍ចុងក្រោយទៅភាគីវិវាទក្នុងរយៈពេល ១២០ ថ្ងៃ ចាប់ពីពេលដែលសាលាក្ដីបានបង្កើត ។ នៅក្នុងករណីជាបន្ទាន់ រួមទាំងទំនិញដែលខូចខាត សាលាក្ដីត្រូវបង្ហាញរបាយការណ៍ចុងក្រោយទៅបណ្ដាភាគីវិវាទក្នុងរយៈពេលកៅសិប (៩០) ថ្ងៃ ចាប់ពីថ្ងៃដែលសាលាក្ដីបានបង្កើត ។ នៅពេលដែលសាលាក្ដីពិចារណាឃើញថាមិនអាចបង្ហាញរបាយការណ៍ចុងក្រោយក្នុងរយៈពេល ១២០ ថ្ងៃ ឬកៅសិប (៩០) ថ្ងៃ ក្នុងករណីបន្ទាន់ទេនោះ សាលាក្ដី

ត្រូវផ្តល់ពត៌មានទៅបណ្តាភាគីវិវាទជាលាយល័ក្ខអក្សរ ដោយរៀបរាប់អំពីមូលហេតុនៃការយឺតយ៉ាវ និងពេលវេលាដែលនឹងត្រូវបង្ហាញ ។ ក្នុងករណីដែលមិនអាចទៅបានចាប់ពីពេលដែលបង្កើតសាលាក្តីរហូតដល់ថ្ងៃបង្ហាញរបាយការណ៍អាចប្រព្រឹត្តទៅ ១៨០ថ្ងៃ ឬ១២០ថ្ងៃ ក្នុងករណីបន្ទាន់ លើកលែងតែមានការឯកភាពណាមួយពីបណ្តាភាគីវិវាទ ។

## ប្រការ ១៣
## ពត៌មាន និងបច្ចេកទេសណែនាំ

១. ពេលដែលមានការស្នើដោយបណ្តាភាគីវិវាទ ឬដោយគំនិតផ្ទាល់ខ្លួន សាលាក្តីអាចស្វែងរកពត៌មាន និងការណែនាំបច្ចេកទេសពីបុគ្គល ឬស្ថាប័នដែលយល់ថាសក្តិសម ។ ពត៌មាន និងការណែនាំបច្ចេកទេសដែលរកបានត្រូវប្រើប្រាស់ឱ្យជាប្រយោជន៍ដល់ភាគីវិវាទ ។

២. គោរពទៅតាមកត្តាវិទ្យាសាស្ត្រជាក់ស្តែង ឬកត្តាបច្ចេកទេសដែលលើកឡើងដោយភាគីវិវាទ សាលាក្តីអាចស្នើសុំរបាយការណ៍ណែនាំជាលាយល័ក្ខអក្សរពីជំនាញការ ឬគ្រប់ជំនាញការ ។ សាលាក្តីអាចស្នើដល់ភាគីវិវាទ ឬទៅតាមគំនិតផ្ទាល់ខ្លួន បន្ទាប់ពីការពិគ្រោះជាមួយភាគីវិវាទ ជ្រើសរើសជំនាញការបច្ចេកទេស ឬវិទ្យាសាស្ត្រដែលជាអ្នកអាចជួយសាលាក្តីតាមរយៈទម្រង់ការសាលាក្តី ប៉ុន្តែគេមិនអាចមានសិទ្ធិបោះឆ្នោតជ្រើសរើសការសំរេចដែលធ្វើឡើងដោយសាលាក្តីឡើយ ។

## ប្រការ ១៤
## ការអនុវត្តន៍របាយការណ៍ចុងក្រោយ

១. របាយការណ៍ចុងក្រោយត្រូវចងក្រងដោយបណ្តាភាគីវិវាទ និងមិនអាចប្តឹងទៅសាលាឧទ្ធរណ៍ ។

២. ប្រសិនបើនៅក្នុងរបាយការណ៍ចុងក្រោយ សាលាក្តីយល់ឃើញថា ភាគីប្តឹងតវ៉ាប្រឆាំងមិនប្រតិបត្តិអនុលោមទៅតាមកាតព្វកិច្ចរបស់ខ្លួនដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងគ្របដណ្តប់ពាក់ព័ន្ធ ឬវិធានការនៃភាគីនាំឱ្យគ្មានតម្លៃ ឬខូចខាត មធ្យោបាយសំរាប់កែតម្រូវសមស្របត្រូវតែលុបចោលការមិនអនុលោមទៅតាមឬការដែលគ្មានតម្លៃ និងខូចខាតទាំងនោះ ។

៣. ក្នុងរយៈពេលម្ភៃ (២០) ថ្ងៃចាប់ពីការបង្ហាញរបាយការណ៍ចុងក្រោយដោយសាលាក្តី បណ្តាភាគីវិវាទ ត្រូវឯកភាពលើ :

ក- វិធីសាស្ត្រសំរាប់អនុវត្តអនុសាសន៍របស់សាលាក្តី និង

ខ- ពេលវេលាសមរម្យចាំបាច់សំរាប់អនុវត្តអនុសាសន៍របស់សាលាក្តី

៤. ប្រសិនមិនមានការឯកភាពពីបណ្តាភាគីវិវាទ ភាគីវិវាទអាចបញ្ជូនបញ្ហាទៅសាលាក្តីដើម ។ ក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃបន្ទាប់ពីថ្ងៃដែលបានបញ្ជូនទៅសាលាក្តី ភាគីប្តឹងតវ៉ាប្រឆាំងអាចស្នើវិធីសាស្ត្រសំរាប់ការអនុវត្តន៍អនុសាសន៍សាលាក្តីដំបូង ។ សាលាក្តីត្រូវកំណត់វិធីសាស្ត្រដូចគ្នាទៅនឹងការស្នើដោយភាគីប្តឹងតវ៉ាប្រឆាំងទៅតាមអនុសាសន៍ និងពេលវេលាសមរម្យ ។ សាលាក្តីត្រូវបង្ហាញរបាយការណ៍ទៅបណ្តាភាគីវិវាទក្នុងរយៈពេលសាមសិប (៣០) ថ្ងៃបន្ទាប់ពីថ្ងៃដែលបញ្ជូនទៅសាលាក្តីដើម ។ គ្មានវិធានការណាមួយត្រូវយកមកប្រើប្រាស់ក្រោមប្រការ១៥ ដោយមិនមានការសំរេចដោយសាលាក្តីដែលមានចែងក្នុងកថាខ័ណ្ឌនេះឡើយ ។

៥. ពេលដែលគ្មានការឯកភាពទៅលើវិធានការដែលមានស្រាប់ចំពោះអនុសាសន៍របស់សាលាក្តីក្នុងរយៈពេលដែលសមរម្យ នោះវិវាទត្រូវបញ្ជូនទៅតាមសាលាក្តីដើម ។ សាលាក្តីត្រូវបង្ហាញរបាយការណ៍របស់ខ្លួននៅក្នុងរយៈពេលសាមសិប (៣០) ថ្ងៃបន្ទាប់ពីថ្ងៃបញ្ជូន ។

## ប្រការ ១៥
## ការទូទាត់សង និង ការព្យួរសម្បទាន ឬផលប្រយោជន៍

១. ការទូទាត់សង និង ការព្យួរសម្បទាន ឬផលប្រយោជន៍ គឺជាវិធានការបណ្តោះអាសន្នដែលអាចរកបានក្នុងករណីដែលអនុសាសន៍មិនបានអនុវត្តទៅតាមក្នុងរយៈពេលសមរម្យ ។ ក៏ប៉ុន្តែទាំងការទូទាត់សង ទាំងការព្យួរសម្បទាន ឬផលប្រយោជន៍ពុំមែនជាការប្រាថ្នាចង់បានដើម្បីការអនុវត្តពេញលេញនៃអនុសាសន៍ក្នុងទិសដៅធ្វើអោយវិធានការស្របតាមកិច្ចព្រមព្រៀងគ្របដណ្តប់នោះឡើយ ។ ការទូទាត់សងគឺធ្វើដោយស្ម័គ្រចិត្តនិងបើយល់ព្រមផ្តល់ក៏ត្រូវស្របតាមកិច្ចព្រមព្រៀងគ្របដណ្តប់ ។៧

២. បើភាគីប្តឹងតវ៉ាប្រឆាំងខកខានមិនបានធ្វើអោយវិធានការដែលបានរកឃើញថាមិនសមស្របតាម កិច្ចព្រមព្រៀងគ្រប់ដណ្តប់ស្របតាមអនុសាសន៍នៃសាលាក្តីក្នុងរយៈពេលសមរម្យដែលបានកំណត់អនុលោមទៅតាមកថាខ័ណ្ឌ ៣ នៃប្រការ ១៤ ភាគីនោះត្រូវចាប់ផ្តើមចរចាជាមួយភាគីប្តឹងតវ៉ាបើមានសំណូមពរចរចា ដើម្បីឈានដល់ការឯកភាពដោយពេញចិត្តទៅវិញទៅមកអំពីការទូទាត់សំណងចាំបាច់ណាមួយ ។

៣. បើគ្មានការព្រមព្រៀងពេញចិត្តទៅវិញទៅមក អំពីការសងត្រូវបានសំរេចក្នុងរយៈពេលម្ភៃ (២០) ថ្ងៃ ក្រោយបន្ទាប់ពីទទួលសំណូមពររបស់ភាគីប្តឹងតវ៉ាអោយចាប់ផ្តើមការចរចាអំពីការទូទាត់សង ភាគីប្តឹងតវ៉ាសរសេរជាលាយល័ក្ខអក្សរទៅភាគីប្តឹងតវ៉ាប្រឆាំង និងភាគីដែលនៅសេសសល់ដទៃទៀតពីគោលបំណងនៃការព្យួរសម្បទាន និងផលប្រយោជន៍ នៃផលប៉ះពាល់ស្មើណាមួយចំពោះភាគីប្តឹងតវ៉ាប្រឆាំង ដែលការព្យួរការនោះអាចចាប់ផ្តើមសាមសិប (៣០) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលលិខិត ។ នៅក្នុងលិខិតនោះត្រូវតែបញ្ជាក់អំពីកំរិតនៃការព្យួរសម្បទាន និងផលប្រយោជន៍ និងកិច្ចព្រមព្រៀងគ្រប់ដណ្តប់ពាក់ព័ន្ធ និងវិស័យដែលសម្បទាន និងផលប្រយោជន៍ពាក់ព័ន្ធ។ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃចាប់ពីថ្ងៃដែលទទួលលិខិត ភាគីប្តឹងតវ៉ាប្រឆាំងអាចសំណូមពរសាលាក្តីដើម្បីបដិសេធរាល់ផលប្រយោជន៍ដែលភាគីប្តឹងតវ៉ាស្នើដើម្បីព្យួរ ដែលស្មើនឹងផលប៉ះពាល់ដែលវិធានការរកឃើញថាមិនត្រឹមត្រូវទៅតាមកិច្ចព្រមព្រៀងគ្រប់ដណ្តប់ពាក់ព័ន្ធ ឬការស្នើព្យួរមិនអនុលោមទៅតាមកថាខ័ណ្ឌ ៤ និង ៥។ ការបដិសេធរបស់សាលាក្តីត្រូវផ្តល់ក្នុងរយៈពេលសែសិបប្រាំ (៤៥) ថ្ងៃចាប់ពីថ្ងៃបានទទួលសំណូមពរ។ សម្បទាន និងផលប្រយោជន៍មិនត្រូវបានព្យួរហូតដល់សាលាក្តីចេញសាលក្រម ។

៤. ការព្យួរសម្បទាន និងផលប្រយោជន៍ណាក៏ដោយត្រូវតែមានល័ក្ខខ័ណ្ឌចំពោះការព្យួរសម្បទាន និងផលប្រយោជន៍ដល់ភាគីប្តឹងតវ៉ាប្រឆាំងនៅក្រោមកិច្ចព្រមព្រៀងគ្រប់ដណ្តប់ពាក់ព័ន្ធទៅតាមកថាខ័ណ្ឌ ៥។ ភាគីប្តឹងតវ៉ាប្រឆាំង និងភាគី សេសសល់ដទៃទៀតត្រូវតែទទួលបានទូវការជូនដំណឹងពីការចាប់ផ្តើម និងសេចក្តីលំអិតនៃការព្យួរនេះ។

៥. ក្នុងការពិចារណាថាសម្បទាន ឬផលប្រយោជន៍ណាដែលត្រូវព្យួរទៅតាមកថាខ័ណ្ឌ ៣ ៖

ក- ជាបឋមភាគីប្តឹងតវ៉ាគួរព្យួរសម្បទាន ឬផលប្រយោជន៍ នៃផ្នែកឬបណ្តាផ្នែកដូចដែលបានប៉ះពាល់ដោយវិធានការទាំងនោះ ឬអ្វីផ្សេងទៀតដែលសាលាក្តីបានរកឃើញថាមិនសមស្របតាមកិច្ចព្រមព្រៀងគ្រប់ដណ្តប់ ឬបានបណ្តាលអោយមានមោឃភាព ឬការបន្ថយ ។

ខ- ភាគីតវ៉ាអាចព្យួរសម្បទាន ឬផលប្រយោជន៍នៃផ្នែកផ្សេងទៀតបើគេគិតថាមិនងាយស្រួលឬមិនមានប្រសិទ្ធិភាពក្នុងការព្យួរសម្បទាន ឬផលប្រយោជន៍នៃផ្នែកដូចគ្នា។

៦. ការព្យួរសម្បទានឬផលប្រយោជន៍ត្រូវតែបណ្តោះអាសន្ន និងត្រូវតែអនុវត្តរហូតដល់ពេលដែលវិធានការដែលបានរកឃើញថាមិនសមស្របតាមកិច្ចព្រមព្រៀងគ្រប់ដណ្តប់ត្រូវបំបាត់ចោល ឬភាគីប្តឹងតវ៉ាប្រឆាំងត្រូវអនុវត្តអនុសាសន៍របស់ សាលាក្តីបានអនុវត្តរួចហើយ ឬដំណោះស្រាយពេញចិត្តទៅវិញទៅមកត្រូវបានសំរេច។

## ប្រការ ១៦
## ភាសាផ្លូវការ

១. ទម្រង់ការទាំងអស់ស្របតាមកិច្ចព្រមព្រៀងនេះត្រូវធ្វើឡើងជាភាសាអង់គ្លេស។

២. ឯកសារណាក៏ដោយដែលបានដាក់ជូនសំរាប់ការប្រើប្រាស់ក្នុងទម្រង់ការស្របតាមកិច្ចព្រមព្រៀងនេះត្រូវតែជាភាសាអង់គ្លេស។ បើឯកសារដើមណាមួយមិនមែនជាភាសាអង់គ្លេស ភាគីដែលបានដាក់ជូនសំរាប់ប្រើប្រាស់ក្នុងទម្រង់ការស្រប តាមកិច្ចព្រមព្រៀងនេះ ត្រូវធ្វើការបកប្រែជាអង់គ្លេសនៃឯកសារនោះ។

## ប្រការ ១៧
## ការចំណាយ

១. ភាគីនីមួយៗត្រូវទទួលខុសត្រូវថ្លៃចំណាយទៅលើសមាជិកសាលាក្តីដែលចាត់តាំងដោយភាគីវិវាទចំណាយផ្ទាល់ខ្លួន និងចំណាយទៅតាមផ្លូវច្បាប់ផ្សេងៗ។

២. លើកលែងតែបណ្តាភាគីវិវាទឯកភាពថ្លៃចំណាយសំរាប់ប្រធានសាលាក្តី និងចំណាយផ្សេងទៀតពាក់ព័ន្ធដល់ការរៀបចំទម្រង់ការត្រូវទទួលខុសត្រូវស្មើភាគគ្នាដោយបណ្តាភាគីនៃវិវាទ។៧

## ប្រការ ១៨
## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធស្ដីពីវិធាន និងនីតិវិធីទំរង់ការសាលាក្ដី និងរាល់មាតិការួមបញ្ចូលក្នុងបង្កើតកិច្ចព្រមព្រៀងនេះ ។

## ប្រការ ១៩
## ការកែប្រែ

បទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ អាចកែប្រែតាមរយៈវិសោធនកម្មដោយការឯកភាពទៅវិញទៅមកជាលាយល័ក្ខអក្សរដោយបណ្ដាភាគី ។

## ប្រការ ២០
## កន្លែងតម្កល់ទុក

សំរាប់បណ្ដាប្រទេសសមាជិកអាស៊ាន កិច្ចព្រមព្រៀងនេះត្រូវរក្សាទុកដោយអគ្គលេខាធិការអាស៊ានដែលត្រូវផ្ដល់ច្បាប់ដែលមានការបញ្ជាក់ទៅប្រទេសសមាជិកអាស៊ាននីមួយៗ ។

## ប្រការ ២១
## ការចូលជាធរមានបញ្ញត្តិ

១. កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាន នៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៦ ដែលយ៉ាងហោចណាស់សមាជិកអាស៊ានណាមួយ និងកូរ៉េដែលក្នុងចំណោមប្រទេសហត្ថលេខី បានជូនដំណឹងជាលាយល័ក្ខអក្សរទៅបណ្ដាភាគីស្ដីពីការបញ្ចប់នីតិវិធីក្នុងស្រុក ។ នៅក្នុងកាលៈទេសៈដែលនេះមិនបានចូលជាធរមាននៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៦ នោះនឹងត្រូវចូលជាធរមាននៅថ្ងៃទី ១ ខែបន្ទាប់ ដែលយ៉ាងហោចណាស់ប្រទេសសមាជិកអាស៊ាន និងកូរ៉េបានជូន ពត៌មានជាលាយល័ក្ខអក្សរទៅបណ្ដាភាគីស្ដីពីការបញ្ចប់នីតិវិធីក្នុងស្រុក ។

២. នៅពេលបញ្ចប់នីតិវិធីក្នុងស្រុកសំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ភាគីត្រូវសរសេរជាលាយល័ក្ខអក្សរទៅបណ្តាភាគីទាំងអស់។

៣. នៅទីណាដែលភាគីពុំអាចបញ្ចប់នីតិវិធីក្នុងស្រុក សំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះនៅថ្ងៃ ដែលមានចែងក្នុងកថាខ័ណ្ឌ ១ កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមានដោយភាគីនោះពេលដែលជូនពត៌មានជាលាយល័ក្ខអក្សរស្តីពីការបញ្ចប់នីតិវិធីក្នុងស្រុក។

**ជាភស្តុតាង** ដោយមានការអនុញ្ញាតិត្រឹមត្រូវ អ្នកចុះហត្ថលេខាខាងក្រោមនេះបានចុះហត្ថលេខា កិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយវិវាទនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ។

**ធ្វើ** នៅកូឡាឡាំពួរ ម៉ាឡេស៊ី**នៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៥** ជាពីរច្បាប់ជាភាសាអង់គ្លេស។

សំរាប់រដ្ឋាភិបាលប្រ៊ុយណេដារ៉ូសាឡឹម

លឹម ជក សេង
រដ្ឋមន្ត្រីទី២ នៃក្រសួងការបរទេស និងពាណិជ្ជកម្ម

សំរាប់រាជរដ្ឋាភិបាលកម្ពុជា

ចម ប្រសិទ្ធ
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូណេស៊ី

ម៉ារី អែលកា ប៉េងជីទូ

រដ្ឋមន្ត្រីពាណិជ្ជកម្ម

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

សូលីវង់ ដារាវង់

រដ្ឋមន្ត្រីពាណិជ្ជកម្ម

សំរាប់រដ្ឋាភិបាលម៉ាឡេស៊ី

រ៉ាហ្វីដា អាស៊ីស

រដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិ និង ឧស្សាហកម្ម

សំរាប់រដ្ឋាភិបាលសភាពមីយ៉ាន់ម៉ា

ស៊ូ ថា

រដ្ឋមន្ត្រីក្រសួងផែនការជាតិ និងអភិវឌ្ឍន៍សេដ្ឋកិច្ច៧

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន

ផីតថី បី ហ្វាវិឡា

រដ្ឋមន្ត្រីពាណិជ្ជកម្ម និង ឧស្សាហកម្ម

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋសឹង្ហបូរី

លឹម អ៊ុង គៀង

រដ្ឋមន្ត្រីពាណិជ្ជកម្ម និង ឧស្សាហកម្ម

សំរាប់រដ្ឋាភិបាលថៃឡង់ដ៍

សំគីត ចាទូរីពីតាក់

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីពាណិជ្ជកម្ម

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម

ជឿង ឌិញ ទៀន

រដ្ឋមន្ត្រីពាណិជ្ជកម្ម៧

សំរាប់រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ

គីម យ៉ុន ចុង

រដ្ឋមន្ត្រីពាណិជ្ជកម្ម ៧

# ឧបសម្ព័ន្ធ
# វិធាន និង នីតិវិធីសំរាប់ទម្រង់ការសាលាក្តី

**បែបបទ**

១. វិធានទាំងនេះបង្កើតឡើងក្រោមប្រការ ១០ នឹងត្រូវអនុវត្តចំពោះទំរង់ការសាលាក្តីក្រោមកិច្ច ព្រមព្រៀងនេះលើក លែងតែបណ្តាភាគីវិវាទឯកភាពផ្សេងពីនេះ ។

២. រាល់ឯកសារយោងទាំងឡាយណាដែលមានចែងនៅក្នុងវិធានទាំងនេះ សំរាប់ប្រការណាមួយ គឺជាឯកសារ យោងដ៏សមរម្យទៅកិច្ចព្រមព្រៀងនេះ ។

**លក្ខខណ្ឌនៃសាលាក្តី**

៣. សាលាក្តីមានលក្ខខណ្ឌដូចខាងក្រោម លើកលែងតែភាគីវិវាទឯកភាពផ្សេងពីនេះ ក្នុងរយៈពេលដប់ (១០) ថ្ងៃចាប់ពីកាលបរិច្ឆេទនៃការបង្កើតសាលាក្តី :

> "ដើម្បីពិនិត្យរាល់បទបញ្ញត្តិពាក់ព័ន្ធ (ឈ្មោះនៃរាល់កិច្ចព្រមព្រៀងគ្របដណ្តប់ដកស្រង់ដោយភាគីវិវាទ) បញ្ហាដែលទាក់ទងទៅនឹងការស្នើសុំបង្កើតសាលាក្តីអនុលោមទៅតាមមាត្រា ៥ ការរកឃើញការបញ្ចប់អនុសាសន៍ និងការណែនាំ ប្រសិនបើមានដូចដែលមានចែងនៅក្នុងមាត្រា ១១ និងការបង្ហាញពីរបាយការណ៍សរសេរដែលមានចែងនៅក្នុងមាត្រា ១១ និង ១២ "

៤. បណ្តាភាគីវិវាទត្រូវប្រគល់ឱ្យទាន់ពេលនូវលក្ខខណ្ឌសាលាក្តីដែលបានឯកភាព ។ សាលាក្តីត្រូវលើកឡើងពីបទញ្ញត្តិដែលពាក់ព័ន្ធនៅក្នុងកិច្ចព្រមព្រៀងដែលបានដកស្រង់ដោយភាគីវិវាទ ។

**ការផ្តល់ជូនឯកសារសរសេរ និងឯកសារផ្សេងៗ**

៥. ភាគីវិវាទនីមួយៗត្រូវប្រគល់ឯកសារសរសេរដំបូងមិនតិចជាងបួនច្បាប់ទៅសាលាក្តី និងមួយច្បាប់ទៅភាគីវិវាទផ្សេងទៀត ។

៦. ភាគីប្តឹងតវ៉ាត្រូវប្រគល់ឯកសារសរសេរដំបូងទៅភាគីប្តឹងតវ៉ាប្រឆាំងមិនឱ្យតិចជាងម្ភៃ (២០) ថ្ងៃ ចាប់ តាំងពីកាលបរិច្ឆេទបង្កើតសាលាក្តី។ ភាគីប្តឹងតវ៉ាប្រឆាំងត្រូវផ្តល់ឯកសារសរសេរទៅភាគីប្តឹងតវ៉ាមិនឱ្យតិចជាងម្ភៃ (២០) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដែលបានទទួលឯកសារសរសេរដំបូងពីភាគីប្តឹងតវ៉ា។

៧. គោរពទៅតាមការស្នើ ការកត់សំគាល់ ឯកសារផ្សេងៗដែលពាក់ព័ន្ធទៅទំរង់ការសាលាក្តីដែលមិនមានចែងនៅក្នុងកថាខ័ណ្ឌ ៥ និង ៦ ភាគីនីមួយៗនៃវិវាទអាចផ្តល់ឯកសារមួយច្បាប់ទៅភាគីវិវាទដទៃទៀត តាមរយៈទូរសារ អ៊ីម៉ែល ឬតាមមធ្យោបាយជាអេឡិចត្រូនិចផ្សេងទៀត។

៨. នៅពេលណាមួយក៏បាន ភាគីវិវាទអាចធ្វើការកែតម្រូវកំហុសឆ្គងតិចតួចលើសំណើ កំណត់សំគាល់ ឯកសារសរសេ និងឯកសារផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងទំរង់ការសាលាក្តីដោយផ្តល់នូវឯកសារថ្មីដោយ
មានបញ្ជាក់ពីការកែតម្រូវ។

**ប្រតិបត្តិការសាលាក្តី**

៩. ប្រធានសាលាក្តីត្រូវធ្វើជាប្រធានគ្រប់អង្គប្រជុំ។ សាលាក្តីត្រូវផ្តល់អំណាចទៅប្រធានដើម្បីធ្វើសំរេចលើការងាររដ្ឋបាល និងនីតិក្រម។

១០. លើកលែងតែមិនមានចែងនៅក្នុងវិធានទាំងនេះ សាលាក្តីអាចប្រតិបត្តិទៅតាមមធ្យោបាយផ្សេងរួមទាំងតាមរយៈទូរស័ព្ទ ទូរសារ និងបណ្តាញកុំព្យូទ័រ។

១១. មានតែសមាជិកនៃសាលាក្តីដែលអាចចូលរួមក្នុងការពិភាក្សាក្នុងសាលាក្តី ប៉ុន្តែសាលាក្តីអាចពិគ្រោះជាមួយបណ្តាភាគីវិវាទ រក្សាទុកជំនួយការ អ្នកបកប្រែ អ្នកកត់ត្រា នៅពេលដែលមានការទាមទារសំរាប់ទម្រង់ការនឹងត្រូវបានអនុញ្ញាតឱ្យមានវត្តមាននៅពេលពិភាក្សា។ សមាជិកសាលាក្តី និងបុគ្គលដែលអនុញ្ញាតដោយសាលាក្តីត្រូវរក្សាការសម្ងាត់ពីទម្រង់ការសាលាក្តី លើកលែងតែពត៌មានដែលបានផ្សព្វផ្សាយទៅសាធារណៈរួច។

១២. នៅពេលដែលមានសំណួរនីតិក្រមលើកឡើងដែលមិនមាននៅក្នុងរាល់វិធាន សាលាក្តីអាចអនុម័តនីតិវិធីសមរម្យដែលមិនខ្វាស់ទៅនឹងកិច្ចព្រមព្រៀងនេះ លើកលែងតែត្រូវបានពិចារណាថាសំណួរនីតិក្រមអាចប៉ះពាល់ដល់របៀបរបបសំខាន់ដែលជាវិធីសំរាប់ពិនិត្យពីមុនមក ក្នុងករណីនេះ សាលាក្តីត្រូវពិគ្រោះជាមួយបណ្តាភាគីវិវាទ ។

១៣. នៅពេលវេលាដែលអាចដំណើរការទៅបានសំរាប់ទម្រង់ការសាលាក្តី ត្រូវពន្យារពេលសំរាប់ការចាប់ផ្តើមលើកាលបរិច្ឆេទចំពោះសមាជិកសាលាក្តីណាដែលមិនអាចអាចប្រតិបត្តិ និងបញ្ចប់ទៅតាមកាលបរិច្ឆេទនោះ សមាជិកជំនួសត្រូវបានចាត់តាំង ។

១៤. សាលាក្តីអាចពិគ្រោះជាមួយបណ្តាភាគីវិវាទ ផ្លាស់ប្តូរពេលវេលាដែលអាចប្រតិបត្តិទម្រង់ការសាលាក្តី និងធ្វើការកែប្រែនីតិក្រម និងរដ្ឋបាលទៅតាមទម្រង់ការ ។

១៥. ទីកន្លែងសំរាប់ដំណើការទម្រង់ការសាលាក្តីអាចកំណត់ដោយមានការឯកភាពទៅវិញទៅមករវាងភាគីវិវាទ ។ ប្រសិនបើគ្មានការឯកភាពទីកន្លែងអាចជាទីក្រុងនៃបណ្តាភាគីវិវាទ ដែលដំណើការទម្រង់ការសាលាក្តីដំបូងត្រូវតែនៅទីក្រុងរបស់ភាគីប្តឹងតវ៉ាប្រឆាំង ។

១៦. គ្រប់ភាគីទីបីដែលមានការចាប់អារម្មណ៍ទៅនឹងវិវាទ អាចចូលរួមបង្ហាញគំនិតតាមរយៈការសរសេរទៅដំណើការសាលាក្តីដំបូងដោយបញ្ជាក់គោលបំណង ។ គ្រប់ភាគីទីបីអាចមានវត្តមាននៅក្នុងដំណើរការ សាលាក្តីទាំងមូល ។

១៧. របាយការណ៍បណ្តោះអាសន្ន និងចុងក្រោយនៃសាលាក្តីអាចព្រាងដោយមិនចាំបាច់មានវត្តមាន ពីភាគីវិវាទនៅពេលដែលពត៌មានបានផ្តល់ និងសេចក្តីថ្លែងការណ៍បានធ្វើរួច ។ មតិយោបល់ដែលបានសំដែងនៅក្នុងរបាយការណ៍នៃសាលាក្តីដោយសមាជិកម្នាក់ៗត្រូវតែអនាមិក ។

១៨. តាមការការពិចារណាដែលបានផ្តល់ ការជំទាស់ និងពត៌មានពីមុន សាលាក្តីត្រូវបង្ហាញរបាយការណ៍បណ្តោះអាសន្នទៅភាគីវិវាទដែលរួមទាំងការរៀបរាប់ពីផ្នែកដែលពាក់ព័ន្ធទៅនឹងការពិតនៃវិវាទ និងការជំទាស់នៃបណ្តាភាគីវិវាទ និងការរកឃើញ និងសេចក្តីសន្និដ្ឋានរបស់សាលាក្តី ។ សាលាក្តីត្រូវយល់ព្រមផ្តល់ឱកាសគ្រប់គ្រាន់ដល់

ភាគីវិវាទដើម្បីពិនិត្យមើលរបាយការណ៍បណ្តោះអាសន្នមុនពេលបញ្ចប់ និងដាក់បញ្ចូលទៅក្នុងការពិភាក្សាពីអនុសាសន៍ដោយបណ្តាភាគីដែលខ្វល់ខ្វាយចំពោះរបាយការណ៍ចុងក្រោយ ។

## តារាងពេលវេលា

១៩. បន្ទាប់ពីការពិគ្រោះជាមួយបណ្តាភាគីវិវាទ ប្រធានសាលាក្តីក្នុងរយពេលកាន់តែឆាប់ និងអាចទៅបាន ក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃបន្ទាប់ពីការបង្កើតសាលាក្តី ត្រូវកំណត់តារាងពេលវេលាសំរាប់ដំណើរការសាលាក្តី ។ ក្នុងការកំណត់តារាងពេលវេលាសំរាប់ដំណើរការសាលាក្តី សាលាក្តីត្រូវផ្តល់ពេលគ្រប់គ្រាន់ទៅបណ្តាភាគីវិវាទសំរាប់រៀបចំឯកសារដែលត្រូវផ្តល់ជូនទៅសាលាក្តី ។ សាលាក្តីត្រូវកំណត់កាលបរិច្ឆេទនៃការប្រគល់ឯកសារ ហើយភាគីវិវាទត្រូវតែគោរពទៅតាមកាលបរិច្ឆេតនោះ ។

## សេចក្តីសំរេចរបស់សាលាក្តី

២០. សាលាក្តីត្រូវធ្វើសេចក្តីសំរេចទៅតាមមតិរួម ។ នៅពេលដែលសាលាក្តីមិនអាចឈានទៅរកមតិរួមបាននោះ សេចក្តីសំរេចត្រូវធ្វើឡើងតាមការបោះឆ្នោតដោយសម្លេងភាគច្រើន ។

## ពត៌មានដែលអាចរកបាន

២១. រាល់ការពិភាក្សារបស់សាលាក្តី និងឯកសារដែលបានផ្តល់ដោយបណ្តាភាគីវិវាទត្រូវរក្សាជាការសម្ងាត់គ្មានភាគីវិវាទណាមួយដែលត្រូវបានរារាំងពីការបង្ហាញសេចក្តីថ្លែងការណ៍ពីជំហររបស់ខ្លួនទៅសាធារណៈ ។ បណ្តាភាគីវិវាទត្រូវចាត់ទុកជាសម្ងាត់នូវពត៌មានដែលបានប្រគល់ដោយភាគីវិវាទផ្សេងទៀតទៅសាលាក្តី ដែលភាគីនោះចាត់ទុកថាជាការសម្ងាត់ ។ នៅពេលដែលភាគីវិវាទប្រគល់នូវឯកសារសំងាត់ជាការសរសេរទៅសាលាក្តីបើមានការស្នើដោយភាគីវិវាទដទៃទៀត សាលាក្តីត្រូវផ្តល់ពត៌មានសង្ខេបដែលមិនសម្ងាត់ហើយដែលអាចផ្សព្វផ្សាយទៅសាធារណៈ ។

## លាភការ និងការទូទាត់សង

២២. សាលាក្តីត្រូវរក្សាទុកនូវបញ្ជីចំណាយ និងបញ្ជីសងត្រឡប់វិញរាល់ខ្ទង់ចំណាយទូទៅដែលពាក់ព័ន្ធទៅនឹងទម្រង់ការសាលាក្តី រួមទាំងការចំណាយសំរាប់ជំនួយការ អ្នកកត់ត្រា និងបុគ្គលដទៃទៀតដែលអនុលោមទៅតាមកថាខ័ណ្ឌ ១១។